លេងប្រៀនប្រដៅប្ដីអីខ្លាំងម្ល៉េះ !..កុំ.. កុំលេងអញ្ចឹង !..ខ្ញុំព្រមទៅតាមម៉ាក់វាឯងហើយ! .

អ្នកស្រីបណ្ដើរប្ដីចុះពីផ្ទះ ប្រៀបដូចជាប៉ូលីសតាមចាប់អ្នកទោសលួចរត់ចេញពីទីឃុំឃាំង ។ ចេញមកដល់មាត់ច្រក ឃើញនាងធួនប្រពន្ធនាយសននៅអង្គុយសំកុក អ្នកស្រីនោះក៏បោះសម្ដីគ្មានសមគួរ :

- កាធួន !.. ផ្ទះនាងឯងឆាកឡែងចិញ្ចឹមស្រីបនអ្នំះ ? ...មីអត់អំណើត ថ្ងៃក្រោយកុំនាំប្ដីអញមកខូចប្រឡូចអញ្ចឹងទៀត ! ស្ដាប់បានទេ ? សម្ដីដ៏អាស្រូវនេះ ធ្វើឱ្យនារីធួនកើតតូចចិត្តជាទីបំផុត អត់មិនបាននាងក៏តបសម្ដីទៅវិញ :

- លោកស្រី ! គ្រួសារខ្ញុំជាមនុស្សមានឋានៈតូចទាប គ្មានសមត្ថភាពអ្វីទៅអូសទាញលោកប្រុស ឱ្យប្រព្រឹត្តអំពើមិនគប្បីទេ !... មុននឹងលើកទោសដាក់កំហុសមកលើខ្ញុំលោកស្រីពិចារណាមើលសិន...

- យើ កាធួន ! ហ៊ានតមាត់នឹងអញប៉ប៉ែសប៉ែបហ្នឹងផង ... និយាយជាមួយអញប្រយ័ត្នបន្តិចនាងឯង !

លោកផែលធុញទ្រាន់ មិនចង់ឱ្យឮមាត់កវែងឆ្ងាយ ក៏ប្រញាប់ទាញប្រពន្ធចេញទៅ ។

ពេលអ្នកទាំងពីរនោះ ចេញផុតពីភូមិទៅបាត់មួយស្របក់ ទើបឃើញនាយសនហ៊ានបន្ទឹមក្បាលចេញមកជួបភរិយា ។ នាងធួនចាប់ញឹងស៊ក ត្រចៀកប្ដី ហើយទ្រគោះសម្ដីទាំងខឹងសម្បា :



- បងសន !. បងឯងនេះធ្វើឱ្យខ្ញុំលំបាកចិត្តណាស់ !

- លំបាកស្អី ? សនសួរធ្វើដូចជាមិនយកចិត្តទុកដាក់ ។

- បងឯងគ្មានដឹងទេ គេមើលងាយយើងសម្បើមណាស់ ក៏ព្រោះតែយើងរក្សាទុកនារីម្នាក់នោះដើម្បីផ្គាប់ចិត្តលោកផែល ។

- អ្នកស្រីកបាល់ភ្លើងទុំះឬ ? ...

- ចាស

- ហ៊ឺ . . . វាតែប៉ុណ្ណឹងទេហើយ ! . . ចៅហ្វាយប្រុសនិងចៅហ្វាយស្រីសុទ្ធតែជាអ្នកប្រើសិទ្ធិអំណាចដូចគ្នា ! . . . បងមិនដឹងធ្វើម៉េចផ្គាប់ចិត្តត្រូវទេ !

- លោកផែលចៅហ្វាយបងឯងនោះ ជាមនុស្សឥតអៀនខ្មាស ! ឆ្កួតនឹងបុណ្យសក្តិ ឆ្កួតនឹងសេរីភាពពុករលួយចាប់ពីថ្ងៃនេះទៅបងឯងឈប់ធ្វើម៉ូយឱ្យលោកផែល ព្រោះរឿងនេះនាំឱ្យអពមង្គលដល់គ្រួសារយើង !

- បងឈប់ហើយ ! សឹងថាស្បថ . . .

- អើ ឥឡូវនាងសម្ផស្សនោះយកទៅទុកនៅឯណា ?

- បងយកទៅផ្ញើនៅផ្ទះធំសួនក្បែរមាត់ទន្លេឯណោះ !

- ចាស បើបានបណ្ដោះចេញទៅហើយ ឈប់ទៅរវីរវល់ទៀតលើកលែងឱ្យនាងមានសេរីភាពទៅចុះ !

- សនមិនចេញស្តី ...ក៏នាំប្រពន្ធឡើងទៅរកកន្ទែងដេកពួនពេលនោះទៅ ។

* * *

៣

## ពន្លកស្នេហ៍

យប់មិញនោះ សម្ផស្សកើតការរន្ធត់ស្លុតចិត្តក្រៃលែង នាងស្ទើរតែធ្លាក់ខ្លួនទៅក្នុងគណ្ដាប់ដៃបុរសចិត្តព្រាន ដែលប៉ុនប៉ងរំលោភលើរូបរាងកាយ ធ្វើឱ្យនាងបាត់បង់កិត្តិយស និងរងការឈឺចាប់រហូតមួយជីវិត ។ ប៉ុន្តែដោយមានព្រឹត្តិការណ៍ចៃដន្យកើតឡើង នាងក៏ត្រូវបានរំដោះខ្លួនផុតពីការរងគ្រោះទៅវិញ ។

សម្ផស្សបានមកស្នាក់នៅផ្ទះ អ៊ំសួនជិតមាត់ទន្លេ ។ អ៊ំសួនជាចាស់ព្រឹទ្ធាចារ្យមួយរូប ដែលមានចិត្តសប្បុរសចំពោះជនទូទៅ ។ កាលនាយសន ជាក្មួយជីដូនមួយរបស់គាត់ យកនាងសម្ផស្សមកផ្ញើក្នុងពេលយប់នោះ គាត់មិនទាន់បានសួរនាំអ្វីច្រើនទេ ក៏ទទួលឱ្យនាងស្នាក់អាស្រ័យសិន ។ លុះព្រឹកឡើង ទើបគាត់ហៅយុវតីនេះមកសាកសួរដំណើរដើមទងឱ្យបានច្បាស់លាស់ :

- ក្មួយស្រី អ៊ំសុំសួរបន្តិចណ៎ា (អ៊ំសួននិយាយក្នុងទឹកមុខញញឹម) យប់មិញនេះ អាសនក្មួយរបស់ខ្ញុំ បានយកក្មួយមកផ្ញើនឹងអ៊ំសុំកន្លែងឱ្យក្មួយស្នាក់អាស្រ័យមួយយប់ ហើយវាបាននិយាយប្រាប់អ៊ំថាក្មួយទើបធ្វើដំណើរមកពីស្រែ មករកបងប្អូននៅភ្នំពេញនេះ ដែលត្រូវ



បែកបាក់គ្នាដោយសង្គ្រាម ហើយបានទៅសុំផ្ទះវាស្នាក់ តែដោយផ្ទះវាមានភ្ញៀវចង្អៀតពេក បានជាវានាំក្មួយមកផ្ទះអ៊ំ មើល៍រឿងនេះមែនទេក្មួយ ? . . . ក្មួយមានស្រុកកំណើតនៅឯណា ហើយធ្លាប់ស្គាល់សនដែរឬ បានជាមានទំនាក់ទំនងមកសុំទុកទើរលើវានេះ ?

កាលឮអ៊ំ សួនលើកឡើងជាសំនួរព្រមជាមួយ នឹងការបកស្រាយប្រាប់ពីពាក្យសម្ដីរបស់នាយសនដូចនេះ នាងសម្ផស្សបែរជាស្រឡាំងកាំង...នាងមិននឹកស្មានសោះថា នាយសនជាមនុស្សក្រឡិចក្រឡុចប្រើមធ្យោបាយបោកប្រាសចាស់ព្រឹទ្ធាចារ្យនេះ ដោយហ៊ានបំផ្លែងរឿងពិតរបស់នាង ។ នាងគិតថាត្រូវតែជំរាបការពិតដល់អ៊ំសួនដើម្បីសុំគាត់ជួយសង្គ្រោះសន្តោសដល់ជីវិតរបស់នាងផង ។ សម្ផស្សលើកដៃសំពះអ៊ំសួន ហើយចាប់តំណាលរឿង តាំងពីពួកទាហានចាប់ឪពុកនិងរូបនាងយកមកវាយធ្វើបាបនៅភូមិសក្ដិពីរ រហូតដល់ពេលលោកផែលចាប់នាងមកឃុំឃាំងទុកនៅលើផ្ទះនាយសន ប៉ុនប៉ងរំលោភ . . . ។

បានស្ដាប់សម្ដីនាងសម្ផស្ស អ៊ំសួនមានការភ្ញាក់ផ្អើលជាខ្លាំង គាត់នឹកហួសចិត្តនឹងអាកប្បកិរិយារបស់នាយសន ដែលហ៊ានមកនិយាយភូតភរប្រាសចាកការពិត ។

- យី ! . . ពួកអារស់នេះ អាក្រក់ដល់ម្លឹង ! ?
- ចា៎ស ! . . . (សម្ផស្សយំខ្សឹកខ្សួលនៅចំពោះមុខអ៊ំសួន)

គេបានធ្វើបាបខ្ញុំ ... ហើយនៅតែមានបំណងប្រាថ្នាតាមធ្វើបាបរូបខ្ញុំតទៅទៀត សូមធំមេត្តាជួយខ្ញុំផង !

ធំសួនសម្លឹងមើលមុខនាងសម្ផស្សយ៉ាងយូរ ហើយក៏កើតចិត្តអាណិតអាសូរ :

_ នាង !.. អ៊ំមិនបានគិតថា អាសនវាមកកុហកអ៊ំទេ ! ..អ៊ំបានស្គាល់អត្តចរិតរបស់ពួកវាខ្លះដែរលោកផែលស្អីនោះជាមនុស្សល្មោភនឹងស្រីញីណាស់ ! ..ឯអាសនវាជាប់សាច់ឈាមនឹងអ៊ំមែនពិត តែអានេះក៏គំនិតមិនល្អដែរ វាជាមនុស្សឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ រឿងនេះមិនអីទេ ចាំអ៊ំស្ដីប្រដៅវា !

_ ធំ ... ( សម្ផស្សលើកដៃសំពះអ៊ំសួនម្ដងទៀត ) ពេលនេះរូបខ្ញុំឥតមានអ្នកណាជាទីពឹងទេ...

_ មិនអីទេក្មួយ ! ( ធំសួនពោលកាត់ ) ក្មួយនៅជាមួយអ៊ំចុះណ៎ា អ៊ំគ្មានកូនចៅនៅជាមួយទេ កូនស្រីរបស់អ៊ំមានតែម្នាក់បានរៀបចំគ្រួសារហើយ គេក៏បែកទៅនៅរកស៊ីឯទីក្រុងសព្វថ្ងៃមានតែក្មួយប្រុសម្នាក់ប៉ុណ្ណោះដែលនៅថែរក្សាអ៊ំ ហើយគេជានិស្សិតនៅកំពុងសិក្សាទៀតផង ។

ពេលនោះ លេចយុវជនម្នាក់ស្លៀកពាក់ស្អាតបាត ចេញពីបន្ទប់កាន់សំពៀតមួយប្រុងដើរចុះ ចេញដំណើរទៅសាលា អ៊ំសួនក្រឡេកឃើញក៏បន្លឺហៅ :



_ បូរិន្ទ ! ... ចូលមកអាយសិន ! .. ( យុវជនបោះជំហានមកដល់ចំពោះមុខ គាត់ក៏មានប្រសាសន៍បន្ត ក្មួយ !.. ឥឡូវនេះអ៊ំទទួលយកក្មួយស្រីខាងណោះឱ្យនៅជាមួយយើង គ្នាក៏ជាមនុស្សកំព្រីកំព្រាដែរ សូមឯងទទួលស្គាល់រាប់អានគ្នាទៅណ៎ា ។

ចប់សម្ដីអ៊ំសួន សម្ផស្សប្រញាប់ងើបមុខឡើង លើកដៃសំពះសួរអ្នកកម្លោះ :

_ ជំរាបសួរបងប្រុស !

_ បាទលើកដៃថ្វាយព្រះ ! បូរិន្ទបន្លឺតបក្នុងទឹកមុខរីករាយ ។

អ៊ំសួនប្រញាប់សារុបសេចក្ដី ដើម្បីបញ្ចប់ការជួបជុំគ្នានៅលើកដំបូង ។

. អើ! ទទួលស្គាល់គ្នាតែប៉ុណ្ណេះបានហើយណ៎ា បូរិន្ទឯងប្រញាប់ទៅសាលាក៏ទៅចុះ ឯក្មួយសម្ផស្សក៏ទៅរៀបចំបន្ទប់មួយនោះសំរាប់ស្នាក់អាស្រ័យ និងជួយមើលកិច្ចការផ្សេងៗនៅក្នុងផ្ទះរបស់អ៊ំនេះផង ។

ពេលអ្នកទាំងពីរបែកចេញពីគ្នាទៅ អ៊ំសួនក៏រៀបចំខ្លួនប្រុងចេញដំណើរទៅវត្តដែរ ប៉ុន្តែពេលនោះ ស្រាប់តែឃើញនាយសនស្លៀកពាក់ក្នុងសណ្ឋានយោធា ដើរមកយ៉ាងសង្ហា ។ សម្ផស្សឃើញនាយសនទឹកភ័យព្រួច ក៏គេចមុខចូលទៅសម្ងំធ្វើការបោសសំអាតបន្ទប់ដែលអ៊ំសួនប្រគល់ឱ្យនាងស្នាក់អាស្រ័យ ។

អ៊ំសួនឃើញលោកតាប៉ូវ៉ាល់ដើរមកបញ្ចេញឫកខែងរែងក៏ហៅមកឱ្យអង្គុយទល់មុខដើម្បីធ្វើការសួរចោទឆ្លើយគ្នាម្ដង ។

- សន ! ឯងថ្ងៃនេះបែបហ៊ឺហាសម្បើមណាស់ ! មកមានការអីឬសន ?

- បាទធំ . . . គ្មានការអ្វីប្លែកទេ គឺមកមើលនាងសម្ផស្ស ដែលខ្ញុំយកមកផ្ញើធំកាលពីយប់មិញនោះ !

- មកមើលនាង ? ( ធំសួនជ្រួញចិញ្ចើម ) មិនបាច់មកមើលមកសួរនាំអីទេ ឯងយកនាងមកទុកនឹងអញ ឥឡូវអញបានថែរក្សានាងបានស្រួលបួលហើយ ! . .

- ខ្ញុំមកសុំយកនាងសម្ផស្សទៅវិញ !

- យកទៅធ្វើអី ? អ៊ំសួនសួរកាត់ !

- បញ្ជាពីលោកដែល ឱ្យមកនាំខ្លួននាងទៅ ដើម្បីសាកសួរចម្លើយព្រោះនាងនេះមានពាក់ព័ន្ធរឿងនយោបាយ . . .

- មិនបាច់មកបោកប្រាសអញទេអាសន យប់មិញឯងនិយាយកុហកអញម្ដងហើយ ! . . អញបានដឹងពីឧបាយកលរបស់ឯងទាំងអស់ ឯងមកយកនាងសម្ផស្សនេះក្នុងគោលបំណងចាប់រំលោភ ធ្វើបាបទៀតមែនទេ ! អាសនអើយ អាឯងគួរតែវៀរចាកអំពើបាបកម្មហើយ ហើយត្រូវមានមនុស្សធម៌នៅក្នុងខ្លួន អាឯងមិនគួរបណ្ដោយខ្លួនដោយរោយតាមចៅហ្វាយនាយរបៀបនោះទេ !



- ហ៊ឺ ! . . អាប់ហើយធំ ឱ្យតែឃើញមុខខ្ញុំកាលណា ចាប់និយាយឡើងស្ដីបន្ទោសតែម្ដង !

- ព្រោះអាឯងជាមនុស្សខិលខូច !

- ថាខ្ញុំខូចក៏បាន តែខ្ញុំខូចនេះក៏ព្រោះតែចៅហ្វាយនាយខិល គឺលោកដែលបង្គាប់បញ្ជាខ្ញុំ ! . . បើខ្ញុំមិនធ្វើតាមបញ្ជា មុខជាគេធ្វើបាបខ្ញុំនិងទម្លាក់បុណ្យសក្ដិ ។

- ហ្នឹងហើយ ! គឺលោកដែលចៅហ្វាយនាយអាឯងនោះ ដែលជាមនុស្សស្មោកគ្រោកក្នុងសង្គម ! . . អាឯងដឹងទេ ពួកអស់លោកធំ ៗ ទាំងនោះ ជាមនុស្សលោភលន់កិបកេងទ្រព្យសម្បត្តិរដ្ឋម្នាក់ ៗ គិតតែបួមមាស ប្រាក់ ធ្វើមានធ្វើបានផ្ទាល់ខ្លួន និងប្រព្រឹត្តនូវអំពើពាលាអាវាសែ ល្បែង ស្រី ស្រា . . . ភាពអនាធិបតេយ្យមានពាសពេញនៅក្នុងទីក្រុង ហើយសព្វថ្ងៃកំពុងតែឈ្លោះទាស់ទែងខ្វែងគំនិតគ្នាដណ្ដើមបុណ្យសក្ដិ . . . អ្នករដ្ឋការបើធ្វើតែរបៀបនេះ អញហ៊ានទាយទុកថា របបសាធារណរដ្ឋខ្មែរ មុខជារលាយឆាប់ !

- យីធំ ( នាយសនពោលដោយភ្ញាក់ផ្អើល ) ហ៊ាននិយាយប៉ះពាល់ដល់សង្គមសាធារណរដ្ឋខ្មែរយើងផង !

- អញនិយាយអញ្ចឹង ! អញគ្មានខ្លាចទេ ព្រោះអញមើលឃើញការពិត គ្មានអស់លោកណាមួយដែលមានមនសិការជាតិត្រឹមត្រូវសោះ ! បើឯងចង់ប្ដឹងអញ ទៅប្ដឹងចុះ !

- អឺហើ ... (សនញញឹមស្ងួត ខ្ញុំផាក្ខយរបស់ធំ ខ្ញុំទៅប្តឹងធំ បានការអី ប៉ុន្តែខ្ញុំសូមជំរាបថា បើធំខឹងខ្ញុំ ដេរតែខ្ញុំបានហើយ កុំដេរ រាលដាលគេប្រយ័ត្នមានរឿង !

- អញចាស់ក្បាលប៉ុណ្ណេះហើយគ្មានខ្លាចរឿងរ៉ាវទេ !

- ចាស់តែអញ្ចឹង !.. តែនិយាយឡើងអួតអាងស្ងាប់ ...

- អាសន កុំចង់បកសម្ដីមកប្រដៅអញ . . . ស្តាប់អញឱ្យច្បាស់ អញនិយាយឱ្យឯងភ្ញាក់ម្ដង !. . អញយល់ហើយថាអាឯងជាអ្នកតូ ធ្វើការបំរើអ្នកធំ ដើម្បីបុណ្យសក្តិប្រាក់កាស . . . តែអញឃើញអាឯ ធ្វើការស្មើរម៉ាអាយុសទៅហើយ គ្មានបានប្រយោជន៍អ្វីទេ! . . បុណ្យ សក្តិកាប៉ូរ៉ាល់អាឯងនេះ ជាបុណ្យសក្តិឡើងតាមជើងខោ កាប៉ូរ៉ាល់ មានតែឈ្មោះ តែគ្មានកូនទាហានទេ !. . សព្វថ្ងៃបានត្រឹមដើរបំរើអ្នក ធំ សំរាប់បោចមាន់ ស្ងោរមាន់ រកស្រា ឱ្យចៅហ្វាយនាយផឹកស៊ី រហូតហ៊ានទៅចាប់កូនក្រមុំគេផ្ដាប់ផ្គុនចៅហ្វាយនាយ ដែលជាមនុស្ស ល្មោភខាងកាមតណ្ហា. ... ឯខ្លួនអាឯងបានត្រឹមតែស៊ីមួយពោះរស់មួយ ខ្លួនប៉ុណ្ណោះ ! . . អាសនអើយ ឯងក្រឡេកមើលជីវភាពប្រពន្ធឯងផង ដែលដើរទូលត្រកួនលក់យ៉ាងល្វេមល្វាម !.. អញប្រាប់ឯងទៅចុះណា៎ ចាប់ពីថ្ងៃនេះទៅត្រូវប្រែចិត្តគំនិត ហើយត្រូវតែវៀរចាកនូវអំពើបាបកម្ម។

ធំស្ងួននិយាយបង្ហាញហេតុផលទាល់តែនាយសនធ្លាក់ទឹកមុខ តែ



នជាមនុស្សរឹងរូសលុះដោយគំនិតខ្មៅកខ្វក់ គ្មានយកចិត្តទុកដាក់ ការពតាមដំបូន្មានទាំងនេះ ក៏នៅតែតមាត់ប៉ប៉ែស :

- ធំ ! ខ្ញុំមកនិយាយសុំយកនាងសម្ផស្សទៅវិញ មិនមែនមក ប់ធំទេសនាស្ដីប្រដៅខ្ញុំទេ !. .

- អាឯងស្តាប់មិនបានទេអ្ហ៎ ? ( ធំស្ងួនប្រើពាក្យធំៗ ) អញបាន ាប់ថានាងសម្ផស្សនេះអញមិនឱ្យឯងយកទៅវិញដាច់ខាត ! ព្រោះ ញឃើញនាងលង់ទឹកត្រូវតែស្រង់ ! មិនបណ្ដោយឱ្យពួកអាស្រោច ុសឯងយកគេទៅធ្វើបាបទេ !

- បើធំនិយាយអញ្ចឹង តើឱ្យខ្ញុំទៅដោះស្រាយជាមួយលោកផែល ៉ាងម៉េចវិញ ?

- ដោះស្រាយយ៉ាងម៉េច ដោះស្រាយទៅ ស្រេចលើក្បាលចិត្ត តែអញប្រាប់ឱ្យហើយ កុំមកធ្វើផ្ដេសផ្ដាសចំពោះនាងទៀត !

នាយសនទ័លតិរៈ អង្គុយកេះក្រចកអស់ពេលយ៉ាងយូរទើបក្រោក ចេញពីផ្ទះអិស្ងួនទៅ ។

*

* *

ចាប់តាំងពីបាននៅស្ថិតស្ថេរលើគេហដ្ឋានអិស្ងួន នាងសម្ផស្ស នយកចិត្តទុកដាក់ខិតខំធ្វើការគ្មានទំនេរដៃ ។ នាងនឹកសរសើរដល់ ាសនារបស់ខ្លួន ដែលចេះបានមកជួបភពប្រសព្វលើមនុស្សចិត្តធម៌ល្អ ដែលនាងត្រូវតែខិតខំគោរពប្រណិបត្តិគាត់ទុកដូចជាឪពុកបង្កើត។

អាកប្បកិរិយាសុភាពរាបសារ និង ស្មារតីឧស្សាហ៍ព្យាយាមក្នុងការងាររបស់នាងសម្ផស្ស បានធ្វើឱ្យអ៊ំសួនស្រឡាញ់រាប់អាននាងជាខ្លាំង ។ លើសពីនេះ ក៏មិនដឹងជាមាននិស្ស័យអ្វីមួយដែលធ្វើឱ្យយុវជនបូរិន្ទ ចេះតែខំពិចពិលរមិលមើល និងមានការពេញចិត្តចំពោះមាណវី ។

បូរិន្ទ ជាយុវជនកំព្រាមានអាយុម្ភៃបួនឆ្នាំ ។ ឪពុក ម្ដាយ របស់គេមានដើមកំណើតនៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ប៉ុន្តែដោយសារសង្គ្រាមទម្លាក់គ្រាប់បែករបស់ចក្រពត្តិអាមេរិក គាត់ក៏ស្លាប់បាត់បង់ជីវិតអស់ទៅ ។ បូរិន្ទ បានមកនៅសិក្សាឯទីក្រុងភ្នំពេញនេះតាំងពីក្មេង កំព្រាតែលតោលម្នាក់ឯង ហើយបាននៅទុកទើរក្នុងបន្ទុកអ៊ំសួន ដែលត្រូវជាឪពុកធំរៀងរហូតមក ។ សព្វថ្ងៃ គេជានិស្សិតនៃមហាវិទ្យាល័យអក្សរសាស្ត្រ ។

ចាប់តាំងពីមាននាងសម្ផស្សចូលមកនៅក្នុងផ្ទះនេះ បូរិន្ទដែលពីដើមខិតខំរៀនផងនិងធ្វើការបំរើឪពុកធំផង ក៏បានធូរដៃជើងយ៉ាងច្រើន។ កិច្ចការក្នុងគ្រួសារនេះ ត្រូវបានសម្ផស្សទទួលរ៉ាប់រងទាំងអស់ ។ នាងជាយុវនារីឧស្សាហ៍ធ្វើការមិនដាក់ដៃជើង ។ ទិដ្ឋភាពនៅក្នុងភូមិ និងស្ថានភាពនៅលើគេហដ្ឋានអ៊ំសួនមានការប្រែលំអនិងស្អាតជានិច្ចបង្កើតបរិយាកាសថ្មីសមជាទីរស់នៅដ៏សុខសាន្តបនោរម្យ ។

រាល់ថ្ងៃបូរិន្ទតែងសង្កេតឃើញ បន្ទប់របស់គេស្អាត ប្រដាប់ប្រដាសៀវភៅរៀនសូត្រដែលធ្លាប់ដាក់រាយប៉ាយនៅលើតុ និង គ្រែដំណេក



លុះគេវិលមកពីសាលាវិញ ក៏ឃើញមានការរៀបចំមានសណ្ដាប់ធ្នាប់។ មុង ភួយ ខោអាវ ដែលប្រឡាក់ត្រូវបាននាងសម្ផស្សយកទៅបោកអ៊ុត រៀបចំទុកដាក់ឱ្យយ៉ាងត្រឹមត្រូវ ។ បូរិន្ទតាមសង្កេតឥរិយាបថនាងសម្ផស្សជាញឹកញាប់ ហើយក៏មានមនោសញ្ចេតនាពេញចិត្ត និងអាណិតនាងកាន់តែខ្លាំងឡើងៗ ។

ថ្ងៃមួយជាថ្ងៃអាទិត្យ ហើយត្រូវចំថ្ងៃសីលដែលអ៊ំសួនមានទម្លាប់ទៅវត្តនៅទាល់ល្ងាច ។ ឯបូរិន្ទ បានឱកាសឈប់សំរាក គេក៏ជិះកង់ដើរលេងបាត់ពីផ្ទះដែរ ។ នៅវេលាម៉ោងដប់មួយទើបបូរិន្ទវិលមកដល់គេហដ្ឋានវិញ។ កាលចូលទៅដល់ក្នុងបន្ទប់គេឃើញស្លកបាររៀបចំទុកនៅលើតុរួចជាស្រេច ។ បូរិន្ទផ្លាស់សម្លៀកបំពាក់ហើយ អង្គុយគិតពិចារណាទៅដល់ការយកចិត្តទុកដាក់របស់សម្ផស្ស នាងជាយុវនារីមួយរូបដែលមានអាកប្បកិរិយា សុភាពរាបសារ ស្មារតីឧស្សាហ៍ព្យាយាម ចេះរៀបចំការងារសព្វមុខ សមជាមេផ្ទះម្នាក់ដ៏ប៉ិនប្រសប់ ។ បូរិន្ទក្រោកដើរទៅកាន់បន្ទប់នាងសម្ផស្ស ។ គេរុញទ្វារចូលទៅស្រាប់តែឃើញមាណវីនេះ កំពុងអង្គុយដេរអាវ ។

សម្ផស្សភ្ញាក់ព្រើត .. ងាកមកឃើញបូរិន្ទក៏នាងមានការអៀនខ្មាសពេកណាស់ ដោយពេលនោះនាងចោមពុងសំពត់ចោលសាច់ស្មាទទេ នាងខំទាញក្រមាមកគ្របដណ្ដប់ប្រញឹបប្រញាប់ ។

- សម្ផស្ស អូនកំពុងធ្វើអីហ្នឹង ?

បុរិន្ទបន្ទឺសូរព្រមទាំងអង្គុយទៅលើកៅអីមួយស្ថិតនៅពីមុខនាង ។ សម្ផស្សងើបមើលបុរិន្ទបន្តិចរួចទម្លាក់មុខចុះ ៖

- ចាស លោកប្រុស ខ្ញុំប៉ះអារ ...

- អ្ហា ... កុំហៅខ្ញុំលោកប្រុសអញ្ចឹង យើងស្ថិតនៅក្នុងយុវវ័យដូចគ្នា ... ហៅខ្ញុំដូចយើងបានជួបគ្នានៅថ្ងៃដំបូង ឬ ហៅត្រឹមឈ្មោះរបស់ខ្ញុំបានហើយ ។

- ចាស ខ្ញុំខ្លាចមិនសមរម្យ ...

- មិនអីទេណា៎សម្ផស្ស អ៊ីបានណែនាំឱ្យយើងពីរនាក់ស្គាល់គ្នា និងចេះស្រឡាញ់រាប់អានគ្នា ។

សម្ផស្សចាប់ញញឹមសើរ ៗ ...

- អូនសម្ផស្ស មានអាវតែមួយហ្នឹងឬ ? (បុរិន្ទសួរបន្ត)

- ចាស មានតែមួយហ្នឹង ។

បុរិន្ទ កដង្ហើមធំ សំដែងឱ្យឃើញនូវការតឹងចិត្តអាណិតដល់ជីវិតអភ័ព្វរបស់នាង ។ គេពោលឡើងតិច ៗ ថា ៖

- ខ្ញុំបានដឹងរឿងពិតពីជីវិតរបស់អូនហើយណា៎សម្ផស្ស តាមរយៈអ៊ីដែលបាននិយាយប្រាប់កាលពីថ្ងៃមុន ... ខ្ញុំទើបបានពិនិត្យឃើញថា សម្ផស្សមកនេះមានសម្លៀកបំពាក់តែមួយប្រផាប់ប៉ុណ្ណោះមែនទេ !

- ចាសបង ... (សម្ផស្សបន្ទឺឡើងអួលដើមក) ។



- អូន ... (បុរិន្ទពោលបង្ហាញចិត្តថ្លើមអាណិតអាសូរ) បងឃើញអូនរស់នៅក្នុងស្ថានភាពបែបនេះ បងមិនអាចនៅស្ងៀមបានទេ ព្រឹកមិញនេះ បងបានទៅផ្សារទិញសារុង សាច់ក្រណាត់សំពត់អាវ នេះនែ៎ បងជូនកញ្ចប់វត្ថុនេះដល់អូន សូមអូនទទួលយកទៅណា៎។

បុរិន្ទហុចកញ្ចប់វត្ថុទៅ សម្ផស្សក៏ទទួលយកទៅឱបជាប់ដើមទ្រូង ហើយគ្រានោះស្រាប់តែនាងចេញទឹកភ្នែករលីងរលោង ទប់មិនបានដលនេត្រពីរតំណក់ក៏ស្រក់ចាកត្របកភ្នែកទាំងគូ ហូរកាត់ថ្ពាល់មកចូលមាត់ ឆាងខំលេបក្លឹក ៗ ...

- អ្ហា សម្ផស្ស ម៉េចក៏អូន អញ្ចឹង ?

សម្ផស្សងើបយឺត ៗ ឡើង មើលចំមុខបុរិន្ទ ព្រមទាំងខំញញឹមកាត់ទឹកភ្នែក ៖

- ចាសបង ... ខ្ញុំរំភើបចិត្តពេក ... ខ្ញុំអរណាស់! ... ជីវិតខ្ញុំដែលកំព្រាមានតែខ្លួនមួយត្រូវរសាត់ខ្សាត់អណ្តែតមកទីនេះ មិននឹកដល់សោះថាបានជួបបងដែលមានចិត្តមេត្តាធម៌ ...

- អូន (បុរិន្ទពោលកាត់) យើងទាំងពីរនាក់ជាមនុស្សកំព្រាកំព្រាដូចគ្នា មានវណ្ណភាពប្រហាក់ប្រហែលគ្នា ត្រូវតែយល់សុខទុក្ខគ្នា... កុំគិតវែងឆ្ងាយអីណា៎សម្ផស្ស អូនយកក្រណាត់នេះទៅកាត់សម្លៀកបំពាក់ទៅ ចាំបងចេញថ្លៃឈ្នួលឱ្យគេ ។

- ចាស អរគុណបងណាស់ ! ន ! ថ្ងៃណាស់ហើយ អញ្ជើញបងទៅហូបបាយទៅ !

បូរិន្ទក្រោកឡើងដើរមកកាន់បន្ទប់ខ្លួនវិញ ។ នាងសម្ផស្សក៏រៀបចំខ្លួនបានសមរម្យហើយដើរមកតាមផ្គត់ផ្គង់បាយទឹកជូនយុវជន តាមភារៈនាងជាអ្នករៀបចំភោជនាហារនៅក្នុងគ្រួសារនេះ ។

*

* *

ពេលវេលាចេះតែកន្លងផុតទៅ ។ ធម្មជាតិទាំងឡាយ តែងមានការប្រែប្រួលនិងបញ្ចេញសោភ័ណភាពថ្មី ទៅតាមកាលរដូវ និង កាលៈទេសៈ ។ យ៉ាងណាមិញ ពន្លកនៃមនោសញ្ចេតនារវាងបូរិន្ទ និងនាងសម្ផស្សដែលកើតមានចំពោះគ្នាកន្លងមកហើយ ក៏ចេះតែរីកដុះដាលឡើងជាលំដាប់ យ៉ាងនោះដែរ ។

ល្ងាចមួយ ពេលព្រលប់ ៗ សម្ផស្សចុះទៅងូតទឹកនៅមាត់កំពង់តាមទម្លាប់រាល់ថ្ងៃ ដែលនាងបានធ្វើកិច្ចការនៅក្នុងផ្ទះហើយ តែងចេញទៅសំអិតសំអាតរាងកាយ ។ នាងមិនបានដាច់ភ្លឹក ស្រាប់តែទូកដែលនាងអង្គុយលូនខ្សាក ! ចេញផុតពីច្រាំង សម្ផស្សប្រហោងពោះធ្លុង !.. នាងងាកទៅស្រាប់តែឃើញបូរិន្ទទំនោរលើក្បាលទូក បញ្ចេញទឹកមុខញញឹម និងសំណើចកក្អឹក ។ បូរិន្ទចាប់ព្រាវអុំទូកចេញទៅកណ្ដាលលំហទន្លេ ។ នាងសម្ផស្សក៏មិនដឹងនិយាយយ៉ាងម៉េច ព្រោះ



នាងកំពុងស្ថិតនៅក្នុងភាពអៀនខ្មាស ដោយដងខ្លួននាងមានតែសារុងចោមពុងសំរាប់ងូតទឹកប៉ុណ្ណោះ ។ នាងខំយកក្រមាមកគ្របដណ្ដប់លើខ្លួនថែមទៀតនិងរៀបចំឥរិយាបថឲ្យបានសមរម្យ ។

ទៅដល់កណ្ដាលទន្លេ បូរិន្ទលែងទូកឲ្យអណ្ដែតតាមចិត្តវា រួចក្រោកឡើងមកអង្គុយជិតនាងក្រមុំ :

- សម្ផស្ស ! អប្បាញ់មិញ ប្រហែលជាអូនភិតភ័យបន្តិចហើយមែនទេ ?

សម្ផស្សញញឹមសើរ ។ បន្ទីរាចាតប :

- ចាស ! អ្នកណាមិនភ័យ បើបងមកពញាក់គេអញ្ចឹង ! ។ បងចេញពីសាលាមកដល់ផ្ទះពីកាលណា បានជាខ្ញុំមិនឃើញ ? .. ស្រាប់តែខ្ញុំមកដល់កំពង់មិនទាន់បានងូតទឹកផង បងមកដល់ដែរ ?

- បងបកពិត ៗ អូនហ្នឹងណា . .. គិតថាមកងូតទឹកជាមួយអូនម្ដង ។

- អី ... គិតអីចឹងទេ ... បងមករកងូតទឹកជាមួយខ្ញុំ ហើយអុំទូកនាំខ្ញុំមកកណ្ដាលទន្លេតែពីរនាក់អីចឹងក្រែង ...

- ក្រែងយ៉ាងម៉េច ?

- ក្រែងអ្នកផងគេថាបងនិងខ្ញុំ យ៉ាងម៉េចៗ នឹងគ្នាទៅ ? . ..

សម្ផស្សធ្លាយវាចាមកបែបនេះ ស្រាប់តែប្រែទឹកមុខឡើងក្រហមបំព្រងដោយទឹកខ្មាសអៀន ព្រោះនាងមិនបានគិតទុកមុន ហើយក៏ស្ថិត

នៅក្រោមគោលបំណងចង់និយាយអីចឹងដែរ ។ បូរិន្ទអស់សំណើចកក្អក រពាលទៅរកនាងវិញ :

– ហ៎ា . . . ! គ្មានអ្នកណាគេរវល់ឈឺឆ្អាលនឹងរឿងយើងទេណ៎ាសម្ផស្ស គេអាចយល់បានទៅហើយថា យុវជន នារីដែលហ៊ានជិះទូកជាមួយគ្នាតែពីរនាក់នៅក្នុងពេលថ្មើរនេះ បើមិនបង ប្អូនរបស់គេ គឺគូសង្សាររបស់គេ ឬ ប្ដីប្រពន្ធរបស់គេ ។

– ចា៎ស ! ប៉ុន្តែបងនិងខ្ញុំ អ្នកជិតខាងបានដឹងថា មិនមែនបងប្អូនបង្កើតនឹងគ្នាតើគេចាត់ទុកជាអ្វីទៅ ? បើសិនជាស្អែកឡើងគេតំណាលសើចពីខ្ញុំ ខ្ញុំខ្មាសគេស្លាប់ហើយបងបូរិន្ទ ។

– សម្ផស្ស មនុស្សម្នាក់ ៗ សុទ្ធតែមានរឿងអាថ៌កំបាំងនៅក្នុងជីវិតខ្លួនគេមិនដែលយករឿងជីវិតរបស់គេទៅលាតត្រដាងប្រាប់អ្នកដទៃអស់ឡើយ បើសិនជាអ្នកណាម្នាក់យករឿងជីវិតគេទៅបរិហារដោយគ្មានហេតុផលចំពោះខ្លួន គឺជាប្រការមិនអាចឲ្យជឿបាន ហើយអ្នកនោះក៏ជាមនុស្សបំផ្លាញសេចក្ដីសុខរបស់អ្នកដទៃ ។ ឯយើងទាំងពីរនាក់ សម្ផស្សយល់ទេ ? បងមានជំនឿជាក់ថា យើងមាននិស្ស័យខាងផ្លូវចិត្តគំនិតដូចគ្នា ឥរិយាបថក្នុងការរស់នៅក៏ដូចគ្នា ហើយគោលបំណងនៃការកសាងទៅអនាគតក៏មិនខុសគ្នាដែរ អ្វី ៗ វាស្ដែងចេញជាមនោសញ្ចេតនាទោរទន់រកគ្នា ហើយមនោសញ្ចេតនាយើងទាំងពីរកំពុងខិតជិតរកគ្នាសព្វថ្ងៃ អូនយល់ថាអញ្ចឹងទេ ?



សម្ផស្សស្ថិតនៅក្នុងសភាពស្ងប់ស្ងៀមអស់ពេលដ៏យូរ។ នាវេលានោះ ស្បៃខ្មៅនៃរាត្រីបានចុះមកគ្របដណ្ដប់លើផ្ទៃមេឃទាំងមូល ។ ខ្យល់ពំនោរក្បាលល្ងាចចាប់ផ្ដាក់មកល្ហើយត្រសៀក ៗ ធ្វើឲ្យផ្ទៃទឹកចាប់រំភើលក៏កើតជារលកតូចៗ រុញច្រានគ្នាទៅបោកផ្ទប់ច្រាំង ឯទូកតូចតាចទាំងឡាយក៏ចាប់ក្រញែងខ្លួនគ្មានឈប់ឈរ ។ ក្នុងលំហមេឃខៀវស្រឡះ លេចព្រះច័ន្ទមួយចំណិតស្ថិតនៅឯនាយចុងព្រៃទិសខាងលិច និងមានហ្វូងតារារះចេញមកព្រោងព្រាត ឆ្លុះពន្លឺចូលទៅក្នុងផ្ទៃទឹកដែលត្រូវរលក ក៏ខ្ទាតរន្ទះឡើងព្រាតៗ ដូចជាគ្រាប់ពេជ្រ ។ ស្ថិតក្នុងពិភពដ៏ស្ងប់ស្ងាត់ពាសដោយភាពអន្ធការនៃរាត្រី សេចក្ដីខ្មាសអៀនទាំងឡាយដែលលេចចេញពីប្រអប់បេះដូងយុវនារី ក៏រលត់រលាយបាត់ខ្លះៗ ដែរ ។ សម្ផស្សហាក់ដូចជាមានសេចក្ដីក្លាហាន ក៏បញ្ចេញវាចាផ្ទោះផ្ទុងទៅកាន់បូរិន្ទ បានយ៉ាងក្លោះក្លាយ :

– បងបូរិន្ទហ៎ា ខ្ញុំមិនទាន់យល់ថា តើបងចង់និយាយអ្វីនឹងខ្ញុំទេ បើសិនជាបងនិយាយក្នុងគោលបំណង ថ្លែងពីមនោសញ្ចេតនារវាងបងនិងខ្ញុំដែលស្រឡាញ់គ្នា តាមភាសាដែលយើងប្រើជាមួយគ្នានៅផ្ទះរាល់ថ្ងៃនោះគឺមិនបាច់សួរចិត្តខ្ញុំទេ ខ្ញុំស្រឡាញ់បងហួសពីស្រឡាញ់ទៅហើយ ! ព្រោះខ្ញុំមានអ្នកឯណាជាទីពឹងក្រៅពីបង ?

– អុញ ! . . . និយាយនេះត្រង់ភ្លឹងដូចពោះអន្ទង់តែម្ដង ! អូនឯងឥតយល់ចិត្តរបស់បងបន្តិចសោះឬ សព្វថ្ងៃបងស្រឡាញ់អូនក្រៅពីបងប្អូនទៅវិញ ?

- អត់ដឹងទេ ! ( សម្ផស្សបន្លឺវាចាតបទាំងញញឹមងាកមុខចេញ ) តើ . . . ស្រឡាញ់ក្រៅពីបងប្អូននោះ គឺ យ៉ាងម៉េច ?

- គឺស្រឡាញ់អូនឯង លើសនេះមួយកំរិតទៀត . . .

- ខ្ញុំឥតយល់ទេ បងបូរិន្ទនិយាយត្រង់ៗមក ខ្ញុំអ្នកស្រែឥតចេះភាសាប្រលោមលោកទេ . . . ចេះតែនិយាយត្រង់ ៗ . . ។

- ងាប់ហើយ ! ឱ្យបងនិយាយយ៉ាងម៉េច បើអូនឯងធំប៉ុណ្ណេះហើយឥតទាន់ដឹងអីអញ្ចឹង ?

បូរិន្ទពោលឡើងក្នុងការតឹងតែងចិត្ត ដូចជាគេសប់ខ្យល់ចូលក្នុងប្រអប់ខួរក្បាល ។ បូរិន្ទជាយុវជនម្នាក់មានការខ្មាសអៀនច្រើនដែរ ហើយជាលើកដំបូងបង្អស់ ដែលចាប់និយាយផ្ដោះផ្ដងជាមួយនារីក្រមុំពីរឿងទំនាក់ទំនងក្នុងជីវិត ។ បញ្ហាដ៏ថ្មីថ្មោងដែលផុសឡើងនៅក្នុងបេះដូងបូរិន្ទ គឺពន្លកនៃសេចក្ដីស្នេហា ប៉ុន្តែសេចក្ដីស្នេហានេះមិនទាន់លូតលាស់ចេញជាត្រួយ ជាស្លឹកទៅក្រៅ ឱ្យនារីដែលជាទីសំណព្វចិត្តរបស់ខ្លួននោះឃើញឡើយ ។ តើគេរកពាក្យអ្វីបកនិយាយឱ្យសម្ផស្សយល់បាន ក្រៅពីពាក្យថា " ស្រឡាញ់ស្នេហា សង្សារគូកំណាន់ចិត្ត គូជីវិត ឬ ប្ដីប្រពន្ធ ?" តាមមើលទៅអត្តចរិតរបស់នាងសម្ផស្ស មានភាពហ្មឹងនរឹងប៉ឹងត្រឹមត្រូវនិងសុភាពរាបសា។ រូបសម្ផស្សនិងឥរិយាបថនេះ វាសក្ដិសមទៅតាមធម្មជាតិដែលបានផ្ដល់ឱ្យនាងពីកំណើតមក ។ បើបូរិន្ទនឹងនិយាយបើកចំហបេះដូងខ្លួនទៅ តើនាងអាចឆ្លើយតបសមតាមបំណងវិញទេ ? ប៉ុន្តែបើសិនជានាងឆ្លើយបដិសេធ... គឺខ្លួនជាមនុស្សដែលមានបេះដូងដ៏កំសាក !បូរិន្ទគិតអញ្ចឹង ។



បូរិន្ទអង្គុយមើលមេឃ មើលផ្កាយមួយសន្ទុះ ទើបនិយាយទៅតាមអារម្មណ៍ដែលគួសវាសមិនត្រូវ ឬ ដូចជាគ្មានទំនុកសំរាប់និយាយ :

- អូនសម្ផស្ស បើអូនមិនយល់ចិត្តបងទេ យើងនិយាយរឿងផ្សេងទៅវិញចុះណ៎ា បងសួរអូនថា ពិភពលោកនេះ អាចខ្វះពន្លឺព្រះអាទិត្យបានទេ ?

- ចាស ! មិនអាចខ្វះបានទេ ប៉ុន្តែក៏មិនត្រូវការរហូតដែរ គឺត្រូវមានទិវានិងរាត្រី ។

- អុញ ! សួរនេះដូចជាមនុស្សម៉ិនគ្រប់ផប់តែម្ដង បូរិន្ទនឹកថាប្រហែលជាសម្ផស្សឆ្លើយ " មិនអាចខ្វះបាន " តែបែរជានាងឆ្លើយចូររហូយទៅតាមក្រិត្យក្រមធម្មជាតិ ។

- អូនឯងចំណាប់គ្រាន់បើ ! ឥឡូវឆ្លើយមួយទៀតមើល៍ អ្វីដែលកើតឡើងនៅក្នុងខ្លួនមនុស្ស ដោយគ្មានអ្នកណាបង្រៀន ស្រាប់តែចេះឯងតែម្ដង ?

- បងបូរិន្ទ សួរចង់ឱ្យខ្ញុំឆ្លើយពីអ្នកណា ?

ឆ្លើយពីខ្លួនបងក៏បាន ខ្លួនអូនឯងក៏បាន . . .

- ហ៊ឺ ! . . បងដាក់ប្រដៅឱ្យគេរកអញ្ចឹង ពិបាកណាស់ ! ខ្ញុំ

គ្មានចេះក្បួនតម្រាអ្វីសោះ តែខ្ញុំឆ្លើយប្រថុយទៅចុះណា៎ ចេះឥតរៀន គឺចេះឃ្លាន ចេះឈឺ ចេះយំ_ចេះសើច...ដល់ធំឡើងចេះ....

_ ចេះអី ?

_ ចេះស្រឡាញ់... ចេះមានសេចក្តីស្នេហា....

សម្ផស្សផ្តាយពាក្យនេះមកស្មើរតែមិនដឹងខ្លួន បុរិន្ទញញឹមមើលមុខយុវតីក្នុងភាពងឹតនោះ មិនដាក់ភ្នែក ហាក់ដូចជាចង់ឱ្យនាងឧទ្ទានពាក្យចុងក្រោយនេះម្តងទៀត ដើម្បីទន្ទេញឱ្យចាំនៅក្នុងបេះដូងទាំងពីរនាក់ ។ សំណួរអម្បាញ់មិញ បុរិន្ទគិតថា វាមិនមែនជាប្រស្នាប្រមូលផ្តុំរាល់គន្ថាសត្យានុមតិតម្រូវឱ្យនាងឆ្លើយបែបនេះទេ តែទឹកចិត្តគេចង់ឱ្យនាងបន្លឺចេញពាក្យនេះ ៖

" ហ្នឹងហើយសម្ផស្ស គឺសេចក្តីស្នេហា" ដែលបងរង់ចាំវាយូរមកហើយ វានោះគឺជាភាពរួមផ្សំរវាងបេះដូងយើងទាំងពីរ បងចង់បានវាមកថ្នាក់ថ្នម បីដូចដួងកែវចរណៃដែលមានរស្មីភ្លឺចិញ្ចាចសំរាប់បំភ្លឺផ្លូវជីវិតយើង ប៉ុន្តែបងមិនទាន់យល់ថា តើអូនយល់ព្រមឬយ៉ាងណាទេ ?

យល់ព្រមចំពោះសេចក្តីស្នេហាយ៉ាងម៉េចបង បើខ្ញុំមិនទាន់យល់ថាសេចក្តីស្នេហានោះជាអ្វីផង ? វាជាទឹកមន្តដែលអាចប្រោះព្រំបេះដូងឱ្យរីកក្រអូបសាយ ឬ វាជាថ្នាំពុលដែលស្រោបរួបរឹតបេះដូងឱ្យរួញស្វិត . . . ?



វាអាចមានបច្ច័យល្អ និងអាក្រក់ដូចអូនគិតអញ្ចឹងមែន ប៉ុន្តែសេចក្តីស្នេហាដែលផុសចេញពីប្រអប់បេះដូងយុវជនដូចរូបបង គឺពិតជាសេចក្តីស្នេហាដ៏បរិសុទ្ធ ស្មោះត្រង់បំផុត ! អូនមិនមានជំនឿចំពោះទឹកចិត្តបងសោះឬ ?

_ ន ! បងបុរិន្ទ ! បងចាំបាច់សួរអូនអញ្ចឹងធ្វើអី ក្នុងយុវភាពរបស់ខ្ញុំ ខ្ញុំឥតចេះនិយាយរឿងនេះសោះ! ប៉ុន្តែបេះដូងរបស់ខ្ញុំក៏មិនមែនជាទឹកកកដែរណា៎ ! ខ្ញុំយល់ថា មានយុវនារីជាច្រើនដែរ ដែលមានបេះដូងដូចខ្ញុំ ដែលមិនសូវចេះនិយាយរឿងនេះ ឬ មិនហ៊ានទម្លាយបេះដូងរបស់ខ្លួនឱ្យអ្នកកម្លោះៗ ដឹង . . . ខ្ញុំឧបមាអីចេះទៅចុះ មានយុវជនម្នាក់តាមស្រឡាញ់យុវតីម្នាក់ដែលគេមិនដឹងខ្លួន ឬមិនដែលស្គាល់ចិត្តគ្នាសោះ ហើយពោលពាក្យលួងលោមថា " បងស្រឡាញ់អូនណាស់ ! អូនស្រឡាញ់បងទេ?" ប្រការនេះ ទោះបី នាងនោះស្រឡាញ់ ក៏ឆ្លើយមិនរួចដែរ . . ។

_ អុញ ! អូនឯងនិយាយប្រៀបធៀបនេះខុសទេ ! រឿងរបៀបនោះផ្សេង ! ឯអូននិងបងមិនដែលស្គាល់ចិត្តគ្នាសោះឬ ?

_ ចាស ! ( សម្ផស្សឆ្លើយទាំងញញឹម ) បើស្គាល់ហើយចាំបាច់សួរដំរិតគេដល់ណាទៀត ? បងសួរឱ្យគេឆ្លើយថា " ស្រឡាញ់ថាស្នេហាៗ " អញ្ចឹងឬ ? មិនបាច់ទេបងអើយ ! សេចក្តីស្មោះស្ម័គ្រនឹងគ្នាដោយពិតៗ មិនស្ថិតលើបបូរមាត់ប្រើពាក្យ " ស្រឡាញ់ ស្នេហាៗ"

នោះទេ  ប៉ុន្តែស្ថិតលើមនោសញ្ចេតនា  អាកប្បកិរិយារបស់នារី សម្តែងចេញជាភាពស្មោះត្រង់ចំពោះបងឬមិនស្មោះត្រង់ ?

- អែយ៉ា ! អូនសម្លស្ស !  បងធ្លាប់ជឿជាក់ខ្លួនឯងថាបងបានរៀនសូត្រយល់ដឹងគ្រាន់បើដែរ  ធ្លាប់មើលសៀវភៅរឿងបុរាណ រឿងប្រលោមលោកដែរមិនដែលឃើញអ្នកនិពន្ធណា  ឱ្យតួអង្គបុរស - នារីជួបគ្នា  ដោយមិនប្រើពាក្យ " សូមស្រឡាញ់ " សូមស្នេហានោះទេ ! អូននិយាយនេះកាច់បងតែម្តង !

- ពាក្យនេះ ចាំបាច់ណាស់ទៅឬ ? បងបូរិន្ទ  យល់អញ្ចឹះទៅចុះ បើសិនជា  សេចក្តីស្នេហានោះ  វាស្តែងឡើងពីទឹកចិត្តស្មោះត្រង់របស់យើងទាំងពីរ វាគង់ជារបស់យើងទេ ! ។ យើងសន្ទនាគ្នាប៉ុណ្ណឹងបានហើយបង តោះទៅផ្ទះវិញ ។

- ទេ ! ( បូរិន្ទសាកល្បងចិត្តនារី  ក៏ទាញដៃនាងមកប្រចាប់តើនាងមានប្រតិកម្មខាងផ្លូវចិត្តចំពោះខ្លួនយ៉ាងណា . . . ) បើអូនមិនឆ្លើយប្រាប់បងច្បាស់លាស់ទេ  បងទុកឱ្យអូននៅកណ្តាលទន្លេនេះដល់ណាណី . . ។

- ងាប់ហើយ ! ឱ្យអូននិយាយយ៉ាងម៉េចទៀតហ្ន៎ . . បើបងមិនយល់អធ្យាស្រ័យចំពោះខ្ញុំ . ខ្ញុំលោតទឹកហែលទៅផ្ទះឥឡូវហ្នឹង!

- អ៊ឹា ! អូនពូកែហែលទឹកដល់ម្ល៉ឹងផង ?



- បងជឿទេ ? ខ្ញុំនៅស្រុកទន្លេ  ដើរលើទឹកដូចដើរលើដីអញ្ចឹង បងចង់ដឹង ថ្ងៃស្អែកយើងហែលទឹកប្រណាំងគ្នាសាកមើល ?

- បងមិនហ៊ានហែលប្រណាំងនឹងអូនឯងទេ ប៉ុន្តែឧបមាថា  អូននាត្រើយម្ខាង  ហើយសភាពការណ៍ចាំបាច់ត្រូវទៅយកអូន  បងស៊ូហែលឆ្លងឱ្យទាល់តែដល់អូន !

- ខ្ញុំក៏អញ្ចឹងដែរ បើបងនៅទីណា  ខ្ញុំសុខចិត្តទៅតាមបងដល់ទីនោះ ! ជឿអូនទេ ?

- ជឿបណ្តោះអាសន្នទៅចុះ !

- ហ៊ាក ! ម៉េចក៏បងពោលអញ្ចឹងទៅវិញ ?

បូរិន្ទអស់សំណើច  ព្រមទាំងចាប់ច្រវាអុំទូកវិលទៅរកច្រាំងវិញ ។

*

*  *

## ៤

# អ្នកលេងស្បែកដាច

រសៀលថ្ងៃនេះ នៅក្នុងការិយាល័យធ្វើការ លោកផែលបា
ហៅកាប៉ូរ៉ាល់សនទៅពិភាក្សាកិច្ចការមួយដ៏សម្ងាត់ តែពីរនាក់
ពេលដែលនាយសនចូលទៅដល់អង្គុយទល់មុខ លោកផែលក៏ចា
និយាយឡើងដោយឥតមានការអៀនខ្មាស :

– សន អញនៅតែនឹកឃើញទៅដល់នារីម្នាក់ឈ្មោះសម្ផស
ដែលអញបានចាប់ចិត្តស្រឡាញ់ ... ស្តាយណាស់វ៉ុ ! កាលណា
រៀបតែសំរេចគោលបំណងទៅហើយ ស្រាប់តែបែរជាមានចង្រៃចៃដន្យកើ
ឡើង ធ្វើឲ្យខកខានទៅវិញ ឥឡូវនេះ ឯងជួយគិតអញម្តងទៀតមើ
ព្រោះអញឮគេថា នារីនោះនៅលាក់ខ្លួនបំពួនអាត្មាក្នុងទីក្រុង
តើឯងរកវិធីណាដើម្បីទាក់ទាញយករូបនាងឲ្យបានដល់អញ ! ។

នាយសនដែលបានចូលមក រង់ចាំស្តាប់សម្តីលោកផែល នឹ
ស្មានខុសថាចៅហ្វាយនាយហៅខ្លួនមកពិភាក្សាពីការងាររដ្ឋ តែផ្ទុ
ទៅវិញបែរជាគាត់លើកយករឿងពុករលួយពាលាអាវ៉ាសែ មកធ្វើ
កម្មវត្ថុនៃកិច្ចពិភាក្សាទៅវិញ ។



– តេជគុណ ! ដូចខ្ញុំបាទបានជំរាបរួចមកហើយថា នារីសម្ផស្ស
នោះបានគេចខ្លួនបាត់ . . .

ក្នុងខណៈដែលសនចាប់និយាយ ចង់បង្ហាញហេតុផលសាជាថ្មី
យាកផែលក្រោកពីកៅអីមកទះស្មា ពោលកាត់ភ្លាម :

– កុំនិយាយរៀបរាប់ប្រាប់អញឡើងវិញសន យើងពុំជឿថា
នាងសម្ផស្សនោះរត់បាត់ទេ យើងបានស៊ើបដឹងថា នារីនោះនៅជិត ៗ
នេះ ហើយមានអ្នកអាណាព្យាបាលដ៏មាំទាំទៀតផង រឿងនេះប្រាកដ
សនឯងបានដឹងច្បាស់ តែឯងមានគំនិតសុបគ្រលំលាក់នាងទុក
ហើយមកភូតភរអញ !

– មិនអញ្ចឹងទេ ទានប្រោស ! ខ្ញុំបាទធ្លាប់ស្មោះត្រង់ចំពោះចៅ
ហ្វាយនាយតេជគុណក៏ដឹងចិត្តស្រាប់ហើយ ប្រើខ្ញុំបាទធ្វើអ្វី បានការ
នោះ ប៉ុន្តែចំពោះនារីម្នាក់នោះ ខ្ញុំបាទពុំអាចនឹងទៅរកនាងមកជូនតេជ–
គុណបានទេ បើតេជគុណត្រូវការនារីដទៃទៀតដែលធ្លាប់រកស៊ីលក់ខ្លួន
ស្រាប់ ចង់ធុនណោក៏បានដែរទានប្រោស !

– ហ៊ា កុំនិយាយអញ្ចឹង ! អញធ្លាប់ជួបប្រសព្វនឹងពួកមេអំពៅ
ស់ទាំងនោះហើយ តែឥឡូវអញត្រូវការនាងសម្ផស្ស ... នាងក្រមុំ
នេះជាកូនខ្មែរអ្នកទន្លេ តែស្អាតហួសពីកូនកាត់ចិន ឬនារីតារាឯកនៃកុន
សៀមទៅទៀត . . . សន យើងនៅតែសង្ឃឹមថា ឯងនឹងអាចយក
នារីនោះបានមកឲ្យយើង ។

- សូមមេត្តាទៅចុះ ទានប្រោស ខ្ញុំបាទពុំដឹងធ្វើដូចម្តេចទេ !

លោកផែលផក់បារីដើរកាត់មុខនាយសន ពីរ បីបក រួចងាកទៅ ដកថតតុ យកក្រដាសប្រាក់មួយបាច់ បោះមកខាងមុខ :

- សន ! ជាមួយអញ ឯងកុំលំបាកពេក ! យកប្រាក់ប្រាំពាន់រៀលនេះទៅចាយវាយទៅ ហើយនាំយកនាងក្រមុំនោះមកឱ្យអញ ! ព្រោះអញកំពុងតែស្រេកឃ្លាន .. ឯងដឹងហើយ ជីវិតអញត្រូវការតែសប្បាយ ប៉ុណ្ណឹងទៅហើយ . . . ហ៏គយកទៅ កុំគិតស្មុគស្មាញច្រើន ! បើឯងចង់ធ្វើគុណធម៌ចំពោះនាងនោះ ក៏វាគ្មានបានផលប្រយោជន៍អីដែរ បើយកប្រាក់គ្រាន់បើផាង ហើយនេះគ្រាន់តែអញឱ្យឯងចាយវាយបន្តិចបន្តួចប៉ុណ្ណោះ បើសិនជាបាននាងមកឱ្យអញមែន ឯងនឹងបានរង្វាន់ច្រើនជាងនេះទៅទៀត ។

នាយសនឃើញប្រាក់ ខំឈរសម្លឹង ហាក់ដូចជាចង់លេបទឹកមាត់ម្តងៗ ។ អានុភាពនៃប្រាក់ដែលមានប្រភេទ ៥០០ ត្រឹមតែដប់សន្លឹកប៉ុណ្ណោះ កំពុងទាក់ទាញទឹកចិត្តសន ធ្វើឱ្យមានការគ្រឡាប់ចាក់មួយរំពេច ។ សនគិតឃើញថា ប្រាក់ប្រាំពាន់រៀល ទោះបីតម្លៃរបស់វានៅក្នុងរបបសាធារណរដ្ឋខ្មែរនេះ ចុះថោកមែនពិត ប៉ុន្តែមិនអាចរកបានដោយងាយ ៗ ទេ ! ក្នុងលោកនាយទុននេះ នរណាហើយដែលមិនត្រូវការប្រាក់ ! ហ៉ាស ! ហ៉ាស ! សំណើចនាយសនផុសចេញពីឈ្ងល់ផ្ទៃក្នុង ។



- តេជគុណ . . . ( សនពោលឡើងបញ្ជាក់ ) បើសិនជាខ្ញុំបាទធ្វើកិច្ចការនេះបានសំរេចតើតេជគុណជួយឧបត្ថម្ភខ្ញុំបាទទៀតមែនឬ?

- យី អាសន ! អញដែលនិយាយភូតអាឯង ? ...

- បាទ ! បើអញ្ចឹង ម្តងនេះ សូមតេជគុណ ចាត់ការឱ្យបានស្អាតបន្តិច ..

- ហ៉ាស ហ៉ាស !.. ( លោកផែលសើចដោយសប្បាយចិត្ត ) មិនអីទេ សនឯងទៅយកនាងឱ្យបានក្នុងល្ងាចនេះមក ហើយយកទៅទុកនៅគ្រឹះស្ថាន " កូឡាបស " បន្ទប់លេខ ២៤ .. កន្លែងដែលអញធ្លាប់ទៅសំរាកសប្បាយម្តងមួយកាលនោះណ៎ា ។

- បាទទាន ! .. តែខ្ញុំបាទខ្លាចតែលោកស្រីតាមដានដឹងទៀត..

- ឆ្កួត ! ... ម្តងនេះ ៖ ញបង្វែងដាន មិនឱ្យលោកស្រីឯងដឹងទេ

- បាទ ! ខ្ញុំនឹងចាត់ការឱ្យបានសំរេចល្ងាចនេះ !

- អើ ! ទៅចុះណ៎ា

សនលូកយកប្រាក់ទាំងញ័រដៃ ហើយចាកចេញមក ក្នុងសភាពឈ្មក់រង្វេង ... ។

ល្ងាចថ្ងៃនោះ ផ្ទះអ៊ំសួនមានសភាពស្ងាត់ស្ងៀម ។ អ៊ំសួនទៅធ្វើបុណ្យនៅវត្តតាំងពីព្រលឹមពុំទាន់វិលមកវិញ ! ឯបុរិន្ទដែលទៅរៀននៅឯភ្នំពេញនោះក៏ពុំទាន់វិលមកដល់ដែរ ។

ប្រហែលម៉ោងប្រាំមួយកន្លះល្ងាច នាងសម្ផស្សដាំស្លរចអង្គុយចាំ

អ្នកទាំងអស់យូរពេក ក៏បិទទ្វារចុះទៅងូតទឹកនៅមាត់កំពង់មួយស្របក់ ។ នាងឡើងមកវិញដល់ពេលងងឹតមែនទែនហើយនាងបើកទ្វារឡើងទៅអុជចង្កៀងលំផុងមួយដាក់នៅលើខ្នងទូអែបជញ្ជាំងនៃល្វែងផ្ទះខាងមុខរួចដើរទៅហាលសម្លៀកបំពាក់នៅយ៉ខាងក្រោយ ។ សម្ផស្សត្រឡប់មកវិញក៏រុញទ្វារបន្ទប់របស់នាងប្រុងចូលទៅអុជចង្កៀងនិងធ្វើការលំអិតសំអាងកាយ ។ ប៉ុន្តែនៅពេលដែលនាងបង្អើបទ្វារបោះជំហានចូលទៅស្រាប់តែមានរូបខ្មៅមួយហក់មកស្ទុះចាប់នាង។សម្ផស្សភ្ញាក់ភ័យស្ទើរ ខ្ញុំស្រែកឡើង ..។រូបស្រមោលខ្មៅនោះគឺកាប៉ូរាល់សន ដែលផាវែសង្កុមលួចឡើងតាមបង្អួចមកសម្ងំនៅក្នុងបន្ទប់ចាំចាប់នាងសម្ផស្សយកទៅបំពើមហិច្ឆតាស្រេកឃ្លានរបស់លោកផែល។ប៉ុន្តែដោយសន មានក្រពក់ផឹកស្រាស្រវឹងជ្រុល ក៏លោតមកចាប់នាងសម្ផស្សខុសទំនង នាងក៏របេះធ្លាយចេញ...ាមមាត់ទ្វារមកក្រៅវិញ ។

– ជួយផង ! ជួយខ្ញុំផង ៗ !

ឮនាងសម្ផស្សស្រែកខ្លាំងដូចនោះ នាយសនស្ទុះចូលប្រុងចាប់តៀកកយកកន្សែងចុកមាត់ :

– ហ៊ឹះ ! ស្រីល្អ កុំខំស្រែកណា៎ ! យើងមិនបណ្តោយឱ្យនាងរួចទេ !

– ទេ !...លោកអើយជួយផង! ជួយផង !..



ខណៈនោះស្រាប់តែឃើញបូរិន្ទរត់ឡើងមក ហើយស្ទុះឆ្ពោះទៅរកសង្គ្រោះសម្ផស្ស :

– អ្ហឹះ ! សន ឯងម៉េចក៏មកធ្វើអញ្ចឹង !.. លែងនាងភ្លាម!..

– យើ ! អាបូរិន្ទ ! អាឯងកុំចូល...អញមិនព្រមលែងនាងនេះដាច់ខាត !

– សន ! មានរឿងហេតុអីប្រាប់យើងសិនមើល ម៉េចបានជាមកធ្វើផ្តេសផ្តាសដូចនេះ ? ...លែងនាងភ្លាមទៅ !.. ឯងស្តាប់អញសិន លែងនាងទៅ !.. លែងទៅ !.. ម៉េចអាឯងមិនព្រមស្តាប់អញទេឬ ? ...ហ៊ឹះ !..

ដោយនិយាយស្តាប់គ្នាមិនបាន ផុតសម្តីនេះ បូរិន្ទក៏ចូលប្រទាញសនពីសម្ផស្ស ហើយបុកមួយកញ្ចប់ដៃចំកំផ្លៀងវាយ៉ាងដំណំ រូបនាយសនក៏ប៉ើងទៅប៉ះជញ្ជាំងគ្រាំង !.. ។ សនជាទាហានវគ្គការពើងចាស់ម្នាក់ ត្រូវមួយដៃមិនទាន់ជាអន់ប៉ុន្មាន ក៏ស្ទុះឡើងក្រទីក្រទារពដាល់បូរិន្ទវិញ តែបូរិន្ទថែមមួយដៃទៀតក៏ស្ងាត់ស្រាលៗ ។ ពេលនោះវាជ្រុះកាំភ្លើងខ្លី ខ្ទាតចេញពីខ្លួន សម្ផស្សស្ទុះស្រវាបានយកមកក្តាប់យ៉ាងណែន តែនាងពុំចេះបាញ់ ។ នាងកំពុងតែញ័រសាច់ភ័យប្រហោងពោះដោយឃើញសនក្រោកឡើងយកបានស្ថានភាពប្រយុទ្ធតបត នឹង បូរិន្ទយ៉ាងខ្លាំងក្លា ។ ឥឡូវនេះ សនដាល់ ទាត់បូរិន្ទ ។ ដាល់ ទាត់សនផាប់ដៃគ្នារក៏រពេញល្វែងផ្ទះ ។ ដោយបូរិន្ទនៅវ័យក្មេង កម្លាំងក៏នៅ

ចាញ់សន ត្រូវសនយកប្រៀបបានវិញ ។ អស់មួយរយៈមក គេឃើញសនសំរុកដាល់បូរិន្ទចូលគប់កៀនជញ្ជាំង ។ នាងសម្ផស្សភ័យតក្កមា ខ្លាចសង្សារត្រូវគ្រោះថ្នាក់ មិនដឹងគិតយ៉ាងម៉េច ក៏ស្ទុះចូលទៅក្របួចកអាវសនពីក្រោយហើយលើកកាំភ្លើងខ្លី បោកចំក្បាលវា ភូស ! ភូស! សនត្រូវពីស្វាយកាំភ្លើងក៏ស្រីឡើងត្រូវបូរិន្ទដាល់ថែមពីរដៃផ្ទួនៗ គ្នាចំក្រ-អូមមាត់ ប៉ើងមកដួលខ្ទោកទៅកណ្ដាលល្វែងផ្ទះ បូរិន្ទខឹងពេកស្ទុះចាប់ផ្ញើយ ។

" អាពីរដៃមុន សំរាប់សងសេចក្ដីឈឺចាប់របស់សម្ផស្ស ! ហើយអាមួយដៃនេះដាក់ឱ្យអាឯងភ្លឺភ្នែក ស្គាល់អញ !

- អួយ ! នាយសនស្រែកហើយក៏រលំទៅលើក្ដារទន់កល្វៀក។

សម្ផស្សស្ទុះមកឱបបូរិន្ទ ដែលផង្អក់ស្មើរតែរលំដែរនោះ ឱ្យហ៊ឹងនវិញ ហើយនាំគ្នាឈរសម្លឹងមើលសន ដែលកំពុងខ្សុរឈាមហូរចេញតាមមាត់មកកក្អាក់ !

ឱកាសនោះ អិស្សនក៏ឡើងមកដល់ឃើញទិដ្ឋភាពដ៏អាស្រូវនេះក៏សាកស្លុតភ្ញាម ។ នាងសម្ផស្សចាប់និយាយប្រាប់ ទើបបានបួន.ដប់-ម៉ាត់ . . . អិស្សនក្ដៅដូចភ្លើងឆួលដើមទ្រូង ក៏ក្រវាត់សំពត់សា និងថង់ស្ពាយទៅកៀនជញ្ជាំង ស្ទុះចូលទៅក្រញាំទាញសក់ក្បាលនាយសន ទះកំផ្លៀកពីរដៃ ៖



- ហ៊ឺះ អាឆ្កែថោកទាប . . . សត្វតិរច្ឆានសោះតែម្ដង ! ... អញបានស្ដីប្រដៅអាឯង ឱ្យដឹងខុសត្រូវ គួរណាស់តែអាឯងស្ដាប់បាន! មិនគួរហ៊ានចូលមកបំពានប្រព្រឹត្តអំពើថោកទាបអញ្ចឹងទៀតសោះ ! អាឯងធ្វើនេះមើលងាយអញពេញទី អាសន !

នាយសនខំបើកភ្នែកដែលហើមប៉ោង មើលអិស្សនភ្លឹះៗ រួចហារមាត់ម្ដុប ៗ ព្រមទាំងលើកដៃសំពះ ។

- មិនបាច់សំពះអញទេអាសន អញមិនមែនជាព្រះសំរាប់ប្រោសអាឯងទេ !

- ធំ . . . សូមធំមេត្តាអាណិតដល់ខ្ញុំផង . . .

- កុំហៅអញធំ ! . . . ចាប់ពីថ្ងៃនេះទៅ ឯងនិងអញគ្មានជាប់សាច់ឈាមទៀតទេ !

- ធំ . . . សូមធំអនុគ្រោះ ខ្ញុំខុសហើយ ! ខ្ញុំធ្វើនេះ គឺមិនមែនចិត្តខ្ញុំចង់ធ្វើទេ ! . . . គេបញ្ជាខ្ញុំៗ ខ្លាចគេ ! .. ខ្ញុំទទួលលុយគេ...

- មើល៍ អ្នកណាបញ្ជា ?

- លោកធែល

- អាក្រពើ ! ចៅហ្វាយនាយអាឯងនិងអាឯងជាអ្នករដ្ឋការ ពួកឯងនេះ គ្មានគិតពីជីវិតជាតិទឹកដីនិងគោរពសិទ្ធិប្រជាពលរដ្ឋទេ ! ពួកឯងប្រើអំណាចផ្ដាច់ការ ! . . . ហើយចំពោះអាឯងចង់ចាប់ក្មួយស្រីនេះទៅ

ផ្ដាប់ចៅហ្វាយនាយពុករលួយ ! អាសនបើអាឯងថ្លើមធំចង់ធ្វើរបៀបនេះ ម៉េចមិនបាញ់អញសម្លាប់សិនទៅ ?

អ៊ិសួន ចាប់កាំភ្លើងបោះទៅឱ្យនាយសន :

– " អាសន ! ឯងជាទាហានរដ្ឋការ បាញ់អញទៅអាសន ! ដើម្បីឱ្យមហាជនគេឃើញផង ! "

នាងសម្ផស្សកើតការព្រួយបារម្ភភ្លាម ឱនខ្សឹបប្រាប់បុរិន្ទ :

– បងអ៊ិខឹងខ្លាំងពេក គាត់បែរជាបោះកាំភ្លើងទៅឱ្យវាអញ្ចឹងតិចវាក្រពុលមុខវាបាញ់មែនទៅ ?

បុរិន្ទឈរប្រចាប់ដៃយុវតី ព្រមទាំងបន្លឺសម្ដីឡើងឱ្យនាងទុកចិត្ត :

– មិនអីទេអូន កាំភ្លើងខ្វីនោះ បងបានដោះគ្រាប់អស់ហើយ ! ទុកចាំមើលវាបើវាហ៊ានងើបតដៃ បងនឹងដាក់បន្ថែមទៀត តែបងយល់ថា វាទ្រាមខ្លួនលែងហ៊ានធ្វើប្រឆេងប្រឆាំងទៀតហើយ ។

អ្នកទាំងពីរឈរសម្លឹងនាយសនមួយសន្ទុះ ក៏នាំគ្នាដើរចេញទៅរានបាយខាងក្រោយ ។ ឱកាសនោះ គេឮមាត់អ៊ិសួនចាប់ស៊ីបន្ទោសនាយសនថែមទៀត ។ សនដឹងខ្លួនថាបានប្រព្រឹត្តខុសក៏ខំប្រេប្រវាចុះតាមជណ្ដើរដោយនាំយកទាំងសេចក្ដីខ្មាសអៀន និងការឈឺចាប់ទៅជាមួយផង ។

*

* *

ចាំបាត់ៗ ហួសម៉ោងណាត់ មិនឃើញនាយសនមកប្រាប់ដំណឹង



លោកធែលកើតអន្ទះសាក្នុងចិត្ត ដើរវិលចុះវិលឡើងក្នុងបន្ទប់ធ្វើការ ដូចសត្វកន្ត្រឡង់ច្រកដប ។ លោកធែលពិនិត្យមើលនាឡិកាដៃជាញឹកញាប់ ហើយអារម្មណ៍កំពុងតែទន្ទឹងនឹងនាំខ្លួនធ្វើដំណើរ ទៅកាន់គ្រឹះស្ថានក្លូឡាបស ទីកន្លែងដែលគាត់បានគ្រោងទុកថា នឹងទៅដេកសោយសុខក្នុងផ្សេកលោកិយដ៏អសោច ។

ម៉ោងប្រាំបីកន្លះយប់ ទូរស័ព្ទលើកទីបីពីគេហដ្ឋានរបស់គាត់ប្រាប់ដំណឹងថា មានភ្ញៀវពិសេសមករង់ចាំពិភាក្សាកិច្ចការមួយដ៏សំខាន់ ។ លោកធែលតប់ប្រមល់ទល់ពុទ្ធោ រកគិតមិនលេច ទីបំផុតឥតមានសេចក្ដីសង្ឃឹម ទើបគាត់ដាច់ចិត្តចុះចាកការិយាល័យទាំងអាការៈមួហ្មង ។

ព្រឹកស្អែកឡើង លោកធែលបានចាត់ទាហានម្នាក់ឱ្យទៅតាមរកកាប៉ូរាល់សន ប៉ុន្តែអ្នកជិតខាងផ្ទះនាយសនបានប្រាប់ថា សនត្រូវប្រពន្ធនាំយកទៅព្យាបាលខ្លួននៅមន្ទីរពេទ្យ ។ ដំណឹងនេះ បានធ្វើឱ្យលោកធែលកើតងឿងឆ្ងល់ ហើយចាត់ទាហានជំនិតឱ្យទៅតាមដានសនដល់មន្ទីរពេទ្យទៀត ។

សនខ្លាចចៅហ្វាយនាយព្យាបាលខ្លួនមិនទាន់បានជាផង ក៏សុំគ្រូពេទ្យចេញមកវិញហើយចូលទៅជួបលោកធែលនៅក្នុងការិយាល័យ ។

– អ៊ុសន ឯងចេញពីពេទ្យមកវិញហើយហ៎ា ?

– បាទ ទានប្រោស ...

– អើ ចុះឯងកើតអី បានជាហើមមុខ ហើមមាត់ បែកថ្ពាសទៅឱ្យគ្រូពេទ្យប៉ង់ស៊ីម៉ង់អញ្ចឹង ?

- បាទ ទានប្រោស ! សននិយាយពេបមាត់ស្បែបចង់យំតែយំមិនចេញ ខ្ញុំបាទរងគ្រោះ ព្រោះតែ...

- ព្រោះតែស្អី ? (លោកផែលសួរ ទាំងចាប់ជ្រួញចិញ្ចើម) ។

សនធ្លាយមាត់បួច :

- ព្រោះតែ ទៅធ្វើកិច្ចការបំរើសេចក្តីស្រេកឃ្លានរបស់តេជគុណ!

- អាជម្ងឺយ៍ ! លោកផែលស្រែកដេរឡូឡា អាឆ្កែងធ្វើកិច្ចការបំរើអញបានស្អីខ្លះ ? អញប្រើអាឯងជាមុខជាមាត់ មិនដែលបានប្រយោជន៍អ្វីទេ !.. ក្រែងអាឯងបានលុយកាក់ពីអញទៅផឹកស៊ីស្រវឹងឈ្លោះទាស់ទែងនឹងគេ ត្រូវគេវាយទេអ្ហី បានជាបែកក្បាល បែកត្បូងអញ្ចឹង ?

សននឹកថា ខ្លួនបានឆ្លើយជ្រុលជ្រួសប៉ះពាល់កិត្តិយសចៅហ្វាយនាយក៏ខំកែកុនសម្តីឡើងវិញ :

- បាទទាន ខ្ញុំបានឈ្លោះនឹងគេមែន...

- អើ ! ឯងធ្វើអាហានយូរហើយចេះស្មៀតប្រយុទ្ធគួរដែរ សព្វបើរឿងឈ្លោះទាស់ទែង វាយតប់គ្នា បើឯងការពារខ្លួនមិនបានទេឱ្យគេវាយងាប់ទៅចុះ !

នាយសនបាត់មាត់ដូចគេចុក ឈរសំកុកចាំស្តាប់ពាក្យស្តីបន្ទោសរបស់លោកផែលតទៅទៀត ។ លុះជននេះ ស្ងប់អារម្មណ៍ទៅវិញបន្តិចគេក៏មានមតិរាយការណ៍ :



- តេជគុណ ខ្ញុំបាទសូមរាយការណ៍ជូន...

- អើនិយាយទៅ ! កុំសូវតេជគុណ ទានប្រោសញយៗពេក !

- បាទតេជគុណ ! រឿងដែលខ្ញុំធ្វើកិច្ចការមិនបានសំរេច ព្រោះមានអាយុវជនម្នាក់ឈ្មោះបូរិន្ទ វានោះហើយដែលបានការពារនាងសម្ពស្ស វាជានិស្សិតនៅមហាវិទ្យាល័យអក្សរសាស្ត្រ វាជាមេខ្លោងម្នាក់ ដែលបានធ្វើសកម្មភាពសម្ងាត់បំផុសបំផុលយុវជនក្នុងសាលាឱ្យធ្វើការតស៊ូប្រឆាំងនឹងរដ្ឋាភិបាលស្រោចស្រង់ជាតិរបស់យើង វាជាមនុស្សមាននិន្នាការនយោបាយក្រហម ធ្វើការបំរើពួករណសិរ្ស និង ពួកវៀតកុង...

- នែ អាភ្លើ ! ( លោកផែលគំហកកាត់ ) អញមិនចង់ស្តាប់អាឯងធ្វើរបាយការណ៍នយោបាយទេ ! អញសួរឱ្យអាឯងឆ្លើយពីរឿងទៅចាប់នាងក្រមុំឈ្មោះសម្ពស្សនោះ វាយ៉ាងម៉េចបានជាមកវិញទទេហើយត្រូវត្បាងគេទៀត ?

- បាទ រឿងនេះ វាមានការទាក់ទិនគ្នា . . .

-ទាក់ទិនអាចំកួតហ្នឹងអី រឿងនយោបាយផ្សេង រឿងស្នេហាផ្សេង

- ស្តាប់ខ្ញុំបាទសិន តេជគុណ ព្រោះតែនិស្សិតម្នាក់នោះហើយដែលធ្វើឱ្យខ្ញុំមានការគ្រោះថ្នាក់ មិនអាចយកនាងសម្ពស្សបាន ។

លោកផែលចាប់ងក់ក្បាលផ្ងក់ៗ ចាប់ដកបារីមកអុជជក់ ទើបពោលៈ

- អឺ . . . និយាយទៅមើល៍ វាបានធ្វើសកម្មភាពអ្វីខ្លះ ?

- បាទ តាមសកម្មភាពជាក់ស្តែងកន្លងមក វាបានធ្វើខិតប័ណ្ណ-ពោះផ្សព្វផ្សាយប្រឆាំងនឹងវត្តមាននៃទីប្រឹក្សាអាមេរិកកាំង ធ្វើបាតុកម្មប្រឆាំងនឹងសង្គ្រាមអាកាសរបស់អាមេរិកនិងធ្វើការតវ៉ា ប្រឆាំងនឹងរដ្ឋា-ភិបាលយើង ដែលធ្វើកំណែនយុវជនសិស្សសាលាចូលទាហាន ។ ឯចំពោះនារីសម្ផស្សនោះ សព្វថ្ងៃនៅជាមួយវា ត្រូវបានវាការពារយ៉ាងម៉ឺងម៉ាត់មិនឱ្យយើងទៅប៉ះពាល់បានឡើយ !

- ហ៊ាស ! ហ៊ាស ! ... លោកផែលផ្ទះសំណើចដ៏គួរខ្លាច សកម្មភាពរបស់ពួកវាទាំងអស់នោះ មិនមែនយើងមិនដឹងសោះទេស កន្លងមក ក្រសួងមានសមត្ថកិច្ចបានតាមដានចាប់ពួកវា បានមួយចំនួ យកទៅដាក់គុកហើយ ! បច្ចុប្បន្នភ្នាក់ងារយើងកំពុងតែតាមស្រាវជ្រា រាវរកពួកវាទៀត មិនអីទេ បើអាបុរិនស្ទីនោះវាខ្លាំងក៏គង់វាស្ទះមិនរួ អំពីអន្ទាក់ពួកគ្រុឌយើងដែរ ។

- បាទ ខ្ញុំបាទក្តៅក្រហាយណាស់ ! ព្រោះអានេះបានវាយគំ ឱ្យខ្ញុំបែកមុខ បែកមាត់ តែដគុណចាត់ការឱ្យរហ័សទៅទាន ។

- អឺ . . . ស្ងប់ចិត្តទៅសន ក្រសួងមានសមត្ថកិច្ចរបស់យើ នឹងចាត់ការឱ្យបានស្អាត ។

* * *



# ៥

# ជីវិតលើខ្សែទឹក

ក្រោយពីកើតមានព្រឹត្តិការណ៍ចាប់គំរាមកំហែងលើរូបនាងសម្ផស្ស មានការព្រួយបារម្ភកាន់តែខ្លាំងឡើង ៗ ។ នាងពិចារណាតែម្នាក់ឯងថា រូបសម្ផស្សរបស់នាង ជាវត្ថុបំណងមួយរបស់ពួកព្រាននារីនៅទីក្រុង ។ ក្នុងជីវិតរបស់នាងដែលមានកំណើតកើតជាចេញពីប្រភពនៃអ្នកស្រែចំការ នាងពុំទាន់ដែលបានយល់ដឹងសោះអំពីរបៀបរបបរស់នៅរបស់សង្គមមនុស្ស ។ នាងតែងគិតថា មនុស្សគ្រប់រូបសុទ្ធតែបានគុណភាពមិនដូចៗ គ្នា មនុស្សមានជីវិតសុទ្ធតែមានវិចារណញ្ញាណត្រឹមត្រូវប្លែកអំពីពួកសត្វដទៃ ដែលមានត្រឹមតែសភាវគតិប៉ុណ្ណោះ ។ ប៉ុន្តែពេលនេះនាងស្គាល់ហើយ មនុស្សនៅក្នុងលោកមូលធននេះ មួយចំនួនមានសារជាតិអាក្រក់ឃោរឃៅរស់នៅពុករលួយជាទីបំផុត ។

ដោយការខ្វះខាតកើតមាននៅក្នុងជីវិត រាល់យប់នាងសម្ផស្សពុំដែលសម្រាន្តបានពេញភ្នែកទេ នាងតែងអង្គុយសំកុករហូតរំលង ៗ អធ្រាត្រ លុះពេលទៀបភ្លឺទើបនាងហ៊ានសម្ងំបានបន្តិចបន្តួច ។ ពេលនិទ្រាលង់លក់ នាងនិមិត្តឃើញតែសភាវៈអាក្រក់កើតមានដល់ដំណើរជីវិត ។ ចុះរាត្រីមួយនាងយល់សប្តិឃើញភ្លើងឆេះព្រៃ ហើយឆ្លួរឆាប

ដល់រូបនាង ដែលកំពុងតែធ្វើដំណើរត្រេចរង្គត់ទៅកាន់ទិសដៅមួយគ្មានទីកំណត់ ។ នាងខំស្រែកឡើងភ្ញាត់សំឡេង... ។

ខណៈនោះ បូរិន្ទដែលកំពុងដេកលង់លក់ ក៏ភ្ញាក់ឡើងភ័យស្ងន់ស្ងោ ។ យុវជនប្រញាប់ស្ទុះចេញទៅកាន់បន្ទប់របស់នាងសម្ផស្សតែស្តាប់ទៅមិនឮមានបាតុភាពអ្វីកើតឡើងឡើយ ។ បូរិន្ទលើកដៃគោះទ្វារព្រមជាមួយនិងសម្តីបន្លឺហៅ :

" សម្ផស្ស .អូនសម្ផស្ស ! "

គេមិនឮសំឡេងនាងឆ្លើយតបមកវិញ នរៈយកដៃរុញទ្វារបន្តិចទៅក៏ស្រាប់តែទ្វារនោះរបើកឡើង គេឃើញសម្ផស្សទៅអង្គុយច្រងុកលើគ្រែ ខ្លួននាងដណ្តប់ដោយកន្សែងពោះគោមួយ ។ បូរិន្ទដើរទៅរុញបង្អួចឱ្យចំហធំ ពន្លឺព្រះចន្ទព្រាលៗ ក៏ជះចូលមកបំភ្លឺផ្ទៃក្នុងបន្ទប់ ។ បូរិន្ទដាក់បង្គួយជិតនាង ទើបដឹងថា នាងកំពុងយំខ្សឹកខ្សួលញ៉ាខ្លួនចំប្រប់ ។

- សម្ផស្ស អូនកើតអីបានជាមិនដេក ហើយទៅអង្គុយយំអញ្ចឹង? ( សម្ផស្សទៅស្ងៀម) អ្នកណាមកធ្វើអ្វីលើរូបអូនទៀតឬ ? អូននិយាយប្រាប់បងមក !

សម្ផស្សបែរមុខមករកបូរិន្ទ ព្រមទាំងបន្លឺវាចាតិចៗ :

- ចាស គ្មានរឿងអីទេ.. តែខ្ញុំដេកមិនលក់ពេះតែខ្លាច

- អូនខ្លាចអី ?



- ចាស ខ្លាចមានមនុស្សយោរយៅ ចូលមកធ្វើបាបខ្ញុំទៀត ព្រោះខ្ញុំចេះតែចាប់ភ្លឹកនឹកឃើញថា រឿងអាក្រក់នៅតែកើតមានដល់រូបខ្ញុំក្នុងពេលខាងមុខទៀត ។

- អូនកុំគិតច្រើនពេកណា ! បងបានគិតគូរដល់ជីវិតរស់នៅរបស់អូនហើយ ដរាបណាមានរូបបងនៅជិតនេះ បងមិនឱ្យពួកជនអន្ធពាលចូលមករំលោភប៉ះពាល់លើរូបអូនបានទេ ។

សម្ផស្សទ្រោបមុខទៅលើទ្រូងបូរិន្ទ បន្លឺវាចាទាំងទង្គិះខ្សឹកខ្សួលតទៅទៀតថា :

- ចាស នៅទីនេះ ខ្ញុំសង្ឃឹមលើតែរូបបងម្នាក់ប៉ុណ្ណោះ បងជាយុវបុរសក្លាហានជាទីទំនុកទុកចិត្តរបស់ខ្ញុំ ខ្ញុំកំព្រាកំព្រាគ្មានទីពឹងណាទៀតទេ សូមផ្ញើកាយចិត្តជីវិតនិងសេចក្តីស្នេហាលើរូបបងតទៅអនាគត សូមបងយល់អធ្យាស្រ័យ ហើយកុំធ្វើឱ្យការលះបង់ចិត្តស្រឡាញ់របស់ខ្ញុំនេះ ក្លាយទៅជាការស្រមើស្រមៃ ឬរឿងមួយដែលស្ថិតនៅក្នុងពិភពនៃការសុបិន ។

បូរិន្ទលើកដៃផង្អែលក្បាលមាណវី និងបញ្ចេញមធុរសវាចា :

- សម្ផស្ស អូនមិនទាន់យល់ និង មានជំនឿសោះឬថាបងមានមនោសញ្ចេតនាស្នេហាចំពោះរូបអូន ? មនោសញ្ចេតនាដែលហូរចេញអំពីបេះដូងរបស់បង គឺជាមនោសញ្ចេតនាល្អបរិសុទ្ធស្មោះត្រង់ពិតៗ វាមានទំហំធំធេងប្រៀបបានចក្រវាឡ ជ្រៅដូចមហាសមុទ្រ ... បងតែង

បានគិតថា ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ យើងទាំងពីរនាក់ត្រូវរួមខ្សែជីវិតជាមួយគ្នា តស៊ូជាមួយគ្នា ។

- ចាស ... សម្ផស្សងើបឡើង យកកន្សែងជូតទឹកភ្នែកចេញ ហើយខំញញឹមរកយុវជននៅក្នុងភាពងងឹត ។

- អូនត្រូវស្ងប់អារម្មណ៍ ហើយគិតគូរដល់ការសំរាកឱ្យបានធម្ម-តាដើម្បីថែរក្សាសុខភាព កុំឱ្យធ្លាក់ខ្លួនទៅជាឈឺថ្កាត់ !

- ចាស ...

ស្អែកឡើង បុរិន្ទបានជំរាបប្រាប់អ៊ំស្រួន និងនាងសម្ផស្សថា គេមានកិច្ចការរវល់មួយយ៉ាងសំខាន់នៅក្នុងសាលា ។ ដល់ពេលយប់គេជាប់រវល់ក្នុងពិធីបើកមហោស្រពកូនសិស្ស ដែលបានប្រព្រឹត្តទៅរហូតដល់ពេលរំលងអធ្រាត្រ ។ ដូចនេះ គេបានបញ្ជាក់ប្រាប់នាងសម្ផស្សរួចជាស្រេចហើយថា គេមិនអាចធ្វើដំណើរវិលមកផ្ទះវិញបានទេ ត្រូវសំរាកនៅសាលានោះតែម្តង ។

ការអវត្តមានរបស់បុរិន្ទនៅក្នុងគ្រួសារនេះ ធ្វើឱ្យនាងសម្ផស្សមានការព្រួយបារម្ភជាប់ជានិច្ច ។ នាងពិចារណាឃើញរឿងថ្មីៗ ទៀតថា ព្រឹត្តិការចាប់រំលោភលើរូបនាងកន្លងមក អាចកើតមានបច្ច័យអាក្រក់ច្រើនយ៉ាងទៀត។នាយសនដែលជាមនុស្សខិលខូច ហើយដែលត្រូវរបួសគ្រោះថ្នាក់បាក់មុខ បាក់មាត់ដោយសារការវាយតប់ជាមួយ



ន្ទ ច្បាស់ជាវាមានគំនុំព្យាបាទមិនលែង បើមិនប៉ងប្រាថ្នាធ្វើបាបរូបនាងទៀត ក៏មានគំនិតចងអាឃាតជាមួយនឹងបុរិន្ទដែរ ។

ប្រហែលម៉ោងដប់យប់ .. អ៊ំស្រួនសម្រាន្តលង់លក់ទៅហើយ ៅតែនាងសម្ផស្សដែលអង្គុយត្រម៉ង់ត្រមោចម្នាក់ឯងក្នុងបន្ទប់ ។ ល់បោកបក់លាន់រំៗ ផ្លះចូលតាមស្លាបព្រិលបង្អួចមកពន្លត់ភ្លើងចង្កៀង លនាងអុជដាក់នៅលើក្បាលគ្រែដំណេក សូរសម្រឹបស្លឹកឈើ ាស់ និង កំទេចមែករុក្ខជាតិងាប់ៗ ជះមកលើដំបូលផ្ទះលាន់ប្រឹបៗ.. ឡេងកូនស្ទើនទ្រហឹងយំអឺងអាប់ទៅក្បែរមាត់ទឹក និងក្នុងគុម្ពចេក ពៅ ។ បើតាមចំណាំចាស់ទុំ សំគាល់បានថា មេឃងងឹតជិតភ្លៀងឬ កជំនន់កំពុងឡើង ។ បរិយាកាសបែបនេះ ធ្វើឱ្យនាងសម្ផស្សមាន រម្មណ៍មិនប្រក្រតី នាងកើតការស្រងេះស្រងោចខ្លោចចិត្ត នឹកទៅ ល់ភូមិករផ្ទះសម្បែង និង ឪពុកកំសត់ដែលត្រូវបែកឃ្លាតអស់រយៈ ពេលពីរខែមកហើយ មិនដឹងជាគាត់ស្លាប់ឬរស់នៅក្នុងស្ថានភាព បែបណា ។

ខណៈនោះ ស្រាប់តែមានសំឡេងគោះទ្វារបន្ទប់ញាប់រន្ថើន ។ សម្ផស្សចាប់ព្រឺក្បាលខ្លាក !.. នាងនឹកគិតថានឹងមានរឿងអាក្រក់ចូល កយាយីរូបនាងទៀត ។

គុក ! គុក ! សំឡេងគោះទ្វារម្តងទៀតស្របនឹងសំឡេងបន្លឺ ហៅ :

- សម្ផស្ស ! អូនសម្ផស្ស !

សម្ផស្សធូរទ្រូងខ្សាក ដោយស្ដាប់បានច្បាស់គឺសំឡេងបូរិន្ទ ។ នាងក្រោកឡើងដើរទៅកាន់មាត់ទ្វារ ។ បូរិន្ទហាក់ដូចជាមានរឿងអាថ៌កំបាំងអ្វីមួយក៏បន្លឺហៅនាងយ៉ាងទាន់ហន់ :

- សម្ផស្ស ! បើកទ្វារប្រញាប់ឡើង !

- បងបូរិន្ទឬ ?

- មែន គឺបងណ៎ា !

សម្ផស្សចាប់បង្អើបទ្វារ ស្រាប់តែបូរិន្ទស្ទុះចូលមកឱបនាងណែន ដោយអាការៈញាប់ញ័រ ។ សម្ផស្សនឹកឆ្ងល់នឹងអាកប្បកិរិយាដ៏ចម្លែកនេះ ក៏ប្រញាប់បន្លឺសួរ :

- ហ៎ាបង ... បងយ៉ាងម៉េចហ្នឹង ?

បូរិន្ទដោះដៃចេញពីរូបនាង រួចអង្គុយដង្ហក់ដូចក្របីថ្មើមមួយត្រូវកំដៅ ។ សម្ផស្សទាញយកក្រមាជូតញើសឱ្យបណ្ដើរ វាចាសួរបណ្ដើរ:

- បងបាននិយាយប្រាប់ខ្ញុំថា ទៅចូលរួមសម្ដែងសិល្បៈទើសភ្លឺ ចុះហេតុយ៉ាងម៉េចក៏វិលបកវិញទាំងថ្មើរហ្នឹង បងកើតជម្ងឺអីឬ ?

- ទេ ! ( បូរិន្ទគ្រវីក្បាល) បងមិនបានទៅរួមក្នុងរាត្រីសមោសរនោះទេ បងមានរឿងធំណាស់ បានជាដោះខ្លួនរត់មកនេះ ។

- បងរត់ ! ?



- ពិតណ៎ាអូន .. មានពួកគិញសម្ងាត់វាចូលទៅរកចាប់រូបបង...

- អ្ហ៎ : !

- រឿងនេះ បើកុំតែមានមិត្តភ័ក្ដិរបស់បងឱ្យបប្រាប់ទាន់ បងត្រូវបានដៃពួកវាទៅហើយ !

- បងនិយាយប្រាប់ខ្ញុំមើល ហេតុយ៉ាងម៉េចបានជាពួកគិញវារកចាប់ខ្លួនបង ?

រឿងវែងឆ្ងាយណាស់ បងគ្មានពេលនិយាយប្រាប់អូនឱ្យអស់សេចក្ដីពិស្ដារទេ .. តែរឿងនេះ បងសន្និដ្ឋានខ្លីថា គឺច្បាស់ជាអាកាប៉ូរាល់សននោះវាទៅប្ដឹងក្រសួងមានសមត្ថកិច្ចឱ្យចាប់រូបបង ។

- ចា៎ស ខ្ញុំសង្ស័យមិនខុស .. អញ្ចឹងបងគិតយ៉ាងណាដើម្បីការពារខ្លួនបាន ?

- យើងអស់សុខហើយអូន . . . ពេលនេះមានបញ្ហាចេញចាប់ខ្លួន ពួកគិញឬពួកប៉េអឹមវាតាមរកចាប់បងឱ្យទាល់តែបាន បងមិនអាចនៅទីនេះបានទេ មានផ្លូវតែមួយគត់គឺគេចខ្លួនចេញពីទីក្រុងជាបន្ទាន់។

- ចា៎ស ! បងគិតគេចចេញអង្កាល់ ?

- ចេញក្នុងយប់នេះ ព្រោះពួកវាអាចមកតាមរកបងដល់ផ្ទះ . .

កាលឮបូរិន្ទនិយាយដូចនេះ សម្ផស្សកាន់តែប្រែមុខស្លេកស្លាំងរកឈាមគ្មាន ។ នាងគិតថា សេចក្ដីសុខ ទុក្ខរបស់បូរិន្ទ គឺជាសេចក្ដីសុខ ទុក្ខរបស់នាងដែរ ។ ពិតមែនតែបូរិន្ទនិងនាងទើបស្រឡាញ់គ្នាជា

គ្រាដំបូងក្នុងឋានៈជាគូកំណាន់ចិត្ត ប៉ុន្តែមនោសញ្ចេតនាស្នេហានៅក្រោមដំបូលផ្ទះតែមួយ រាប់ទុកថាជាប្តីប្រពន្ធស្រេចទៅហើយ ។ ពេលនេះបើបុរិន្ទទៅទីណា នាងក៏សុខចិត្តទៅទីនោះដែរ ។

_ បង ខ្ញុំមិនចង់ឃើញបងនៅត្រូវគេចាប់ចងធ្វើបាបទេ ហើយខ្ញុំក៏មិនអាចរស់នៅរងកម្មតែម្នាក់ឯងបានដែរ បើបងសំរេចចិត្តថាចាកចេញពីទីក្រុងអញ្ចឹង ខ្ញុំឯកភាពតាមបងហើយ បងចេញទៅដំបន់រំដោះតែម្តងក្រែងលោបានសុខ ហើយខ្ញុំក៏សុំទៅជាមួយបងដែរ ។

បុរិន្ទអង្អយទ្រើងសញ្ជឹងគិតមួយសន្ទុះ ទើបពោល :

_ បងមិនឃាត់ឃាំងអូនទេណា៎ ប៉ុន្តែបងនឹកថា បើអូនធ្វើដំណើរទៅជាមួយបង បងខ្លាចអូនលំបាក . . :

_ ខ្ញុំសុខចិត្តលំបាក តស៊ូរស់នៅជាមួយបង ព្រោះខ្ញុំទ្រាំនៅទីនេះក៏គ្មានន័យអ្វីដែរ ឃើញតែអំពើឃោរឃៅអយុត្តិធម៌ រួចខ្ញុំនឹងត្រូវអនុភាពនៃសង្គមពុករលួយគ្របសង្កត់ហើយថ្ងៃណាមួយ នឹងធ្លាក់ខ្លួនទៅ ជាទាសីនៃវណ្ណៈជិះជាន់ដែលល្មោភទៅដោយអំពើកាមគុណខ្ញុំជៀសមិនរួចពីការក្លាយខ្លួនទៅជាស្រីបាតសង្គមដ៏ថោកទាបបំផុត ...បងគិតមើល៍ បើបងទុកខ្ញុំនៅទីនេះតើមានអ្នកណាជួយការពារ យើងនៅបែកគ្នាក្នុងតំណាក់កាលនេះមិនមែនជារឿងធម្មតាទេ តំបន់រំដោះនិងតំបន់រដ្ឋការយុំគ្រងខណ្ឌដាច់ពីគ្នាដោយសមរភូមិនិងភ្លើងសង្គ្រាម យើងគ្មានពេលវេលានឹងលទ្ធភាពដែលអាចទាក់ទងគ្នាបានទេ !



មតិបំភ្លឺរបស់នាងសម្ផស្ស ធ្វើឱ្យបុរិន្ទជ្រះស្រឡះក្នុងចិត្ត យល់ព្រមតាមសំណូមពរនាងភ្លាម :

_ អញ្ចឹង អូនរៀបចំខ្លួនទៅណា៎ :

_ យើងចេញ ឥឡូវនេះឬ ?

_ ចេញឥឡូវនេះ តោះ ! រៀបបង្វេចសម្លៀកបំពាក់ភ្លាមទៅប្រញាប់ទៅលាធំ ។

ក្នុងឱកាសដែលអ្នកទាំងពីរកំពុងគិតគ្នារអ៊ូ ។ រៀបចំប្រដាប់ប្រដាដាក់យកទៅតាមខ្លួន អ៊ិស្សូនក៏ភ្ញាក់ពីដំណេកឡើង អុជចង្កៀងបំភ្លឺ។ គាត់ចាប់បារីសិកស្តែ អុជជក់បង្ហុយផ្សែងទ្រលោមដោយប្រើគំនិតត្រិះរិះគិតបណ្តើរទៅជាមួយផង ។ គាត់រៀបតែនឹងបន្លឺហៅបុរិន្ទនិងនាងសម្ផស្សឱ្យមកជួបនឹងគាត់ ដើម្បីសួរកិច្ចការដែលគាត់កំពុងតែមានការចាប់អារម្មណ៍ តែលំដាប់នោះស្រាប់តែយុវជនទាំងពីរចូលទៅអង្គុយបត់ជើងនៅចំពោះមុខគាត់ ហើយលើកដៃថ្វាយបង្គំព្រមៗ គ្នា ។

អ៊ិស្សូន យល់ជាស្រេចហើយថា អ្នកទាំងពីរដែលបានស្រុះស្រួលចិត្តគ្នា ចូលមកវន្ទាគាត់នៅក្នុងវេលាថ្មើរនេះ ពិតជាមានគោលបំណងសុំការអនុគ្រោះចំពោះសេចក្តីស្នេហារបស់ខ្លួន ឬក៏មានសភាពអ្វីកើតឡើងប៉ះពាល់ដល់ដំណើរជីវិតរបស់ខ្លួន ដែលត្រូវសុំឱ្យគាត់ជួយដោះស្រាយមិនខាន ។ អ៊ិស្សូនស្ថិតនៅក្នុងភាពស្រពាប់ស្រពោន តែទឹកមុខរបស់គាត់បង្ហាញឱ្យឃើញនូវការយោគយល់អធ្យាស្រ័យ និងការ

អាណិតអាសូរយ៉ាងធ្ងន់ធ្ងរ ។ បុរិន្ទចាប់រ៉ាយរ៉ាប់ប្រាប់អំពីឧប្បទ្ទវហេតុដែលកើតឡើង និងគោលបំណងចុងក្រោយរបស់ខ្លួន សុំលាគាត់ចេញទៅតំបន់រំដោះ ។

ធំស្ងួតស្ងិតនៅស្ងៀមមួយសន្ទុះ ដោយមានកំសួលឆ្អួលពិព្ធដ៏ផ្ទៃក្នុងដួងចិត្តរបស់គាត់...គាត់ខំពោលឡើងទាំងរអួលអាក់ :

- បុរិន្ទ...រឿងរបស់ក្មួយ អ៊ំបានដឹង និងយកមកធ្វើការពិចារណាយូរហើយ អ៊ំមិនលើកទោសដាក់កំហុសទៅលើឯងទេណា៎ ព្រោះឯងមានការឈឺចាប់ចំពោះអ្នកកាន់អំណាចប្រតិកិរិយា និងចក្រពត្តិអាមេរិកដែលបានទម្លាក់គ្រាប់បែកសម្លាប់ឪពុកម្តាយរបស់ឯង ឯងជាយុទ្ធជនមានជំហរតស៊ូ និងមានទស្សនបដិវត្ត...អ៊ំក៏ស្អប់ខ្ពើមនូវរបបពុករានេះដែរ ! ប៉ុន្តែអ៊ំចាស់ហើយមិនអាចធ្វើអ្វីបាន ពុំធ្វើបានតែត្រឹមជួយផ្គងផ្តើមដល់រូបឯងប៉ុណ្ណោះ ! ថ្ងៃមុនមិត្តភ័ក្តិរបស់អ៊ំម្នាក់នៅខាងទន្លេតូចបានឆ្លៀតមកលេងនឹងអ៊ំនៅទីនេះ អ៊ំបាននិយាយពីការតស៊ូរបស់ឯងហើយបានស្នើគេថាបើសិនជាសភាពការណ៍ មិនអំណោយផលឱ្យឯងនៅទីនេះបានទេ អ៊ំនឹងបញ្ជូនឯងទៅឱ្យគេជួយថែរក្សាការពារផង គេបានយល់ព្រមដោយរីករាយ ។ ឥឡូវនេះ ចូលដល់ដំណាក់ការធ្ងន់ធ្ងរដែលមិនអាចឱ្យឯងនៅបាន ឯងត្រូវរំដោះខ្លួនចេញ !

- បាទធំ ... ខ្ញុំមកសុំលាធំចេញទៅក្នុងយប់នេះ !.. អូនសម្ផស្សក៏ខ្ញុំសុំយកទៅជាមួយដែរ ។



- អឺ ... អ៊ំមិនថាអីថាវ៉ាន់ទេ ក្មួយទាំងពីរនាក់ទៅចុះ ! ( អ៊ំស្ទួនពោលរួចងាកទៅបើកស្រោមខ្នើយ ទាញយកកូនសំបុត្រមួយហុចមកឱ្យបុរិន្ទ ) " ឯងត្រូវនាំគ្នាធ្វើដំណើរចេញទៅទន្លេតូច រកឈ្មោះបុរសម្នាក់ឈ្មោះ " ជ័យ " នៅភូមិព្រែកជ្រៃ ស្រុកពាមរក៍ ខេត្តព្រៃវែង ... ទៅជួបនឹងគេនោះគេអាចជួយថែរក្សាការពារបាន និងនាំរូបឯងទៅជួបអង្គការបដិវត្តនៅមូលដ្ឋានឱ្យគេទទួលស្គាល់ផង " ។

- បាទធំ ខ្ញុំត្រេកអរណាស់ !

- អឺ ឯងនាំគ្នាទៅកុំបីមានកង្វល់មកលើរូបអ៊ំនៅឯណេះណា៎ អ៊ំក៏មានកូនចៅរស់នៅទីក្រុង គេអាចមកជួយគាំពារថែរក្សាអ៊ំបានហើយ អ៊ំសុំឱ្យក្មួយទាំងពីរនាក់បានជួបតែសេចក្តីសុខចុះ ! ។

បុរិន្ទនិងសម្ផស្សលើកដៃសំពះទន្ទឹមគ្នា អ៊ំស្ទួនលូកចាប់ដៃអ្នកទាំងពីរផ្សំផ្គុំគ្នា ហើយមានប្រសាសន៍បន្ត :

" ក្មួយទាំងពីរ អ៊ំមើលឃើញក្មួយមាននិស្ស័យនឹងគ្នាល្អណាស់ ក្នុងគ្រានេះ អ៊ំសូមផ្សំផ្គុំក្មួយឱ្យបានទទួលគ្នាជាប្តីប្រពន្ធទៅអនាគត សូមក្មួយមានសិរីសួស្តីជ័យមង្គលវិបុលសុខគ្រប់ប្រការ ចេញដំណើរទៅឱ្យបានសំរេចដល់ទីដៅ និងប្រកបដោយសុវត្ថិភាពណា៎ក្មួយ " ។

- សាធុ ! សាធុ ! ( បុរិន្ទនិងសម្ផស្សរៀបទ្ទឹមព្រម ៗ គ្នា ) ។

*

* *